# ឧបករណ៍

# សមថ វិបស្សនា

រៀបរៀងដោយ

ភិក្ខុ ចិន ភេន ឥន្ទប្បញ្ញោ

## វត្តពោធិវង្ស ប្រទេសបារាំង

បោះពុម្ពចែកជាធម្មទាន

លើកទី ១ ចំនួន ១៥០០ ក្បាល

២៥៥.
១៣៩ក

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

២ម៉ែម.១៣៩ក

# ឧបករណ៍

## សមថ វិបស្សនា

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
០២៩៧/០៦

រៀបរៀងដោយ

ភិក្ខុ ថិន គេន ឥន្ទបញ្ញោ
២៣៩

បោះពុម្ពចែកជាធម្មទាន
លើកទី ១ ចំនួន ១៥០០ ក្បាល

ដោយពុទ្ធបរិស័ទ វត្តពោធិវង្ស
ប្រទេសបារាំង

ព. ស. ២៥៤៦ គ. ស. ២០០២

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

៖ ៣ ៖

ខ្ញុំសង្កេតឃើញ មានអ្នកបដិបត្តិធម៌ច្រើនគ្នា ដែលមិនចេះមិនចាំគោលធម៌។ អ្នកមិនចេះ មិនចាំគោលធម៌ ក៏អាចបដិបត្តិធម៌បានសម្រេចប្រយោជន៍ បានសម្រេចមគ្គផលដែរ ប៉ុន្តែ បើគេចេះ គេចាំគោលធម៌ខ្លះផង វាជាការល្អ សំរាប់ខ្លួនគេ និងសំរាប់ជួយអ្នកឯទៀតផង ។

ដើម្បីជួយឲ្យងាយស្រួលក្នុងការចេះចាំគោលធម៌ ទើបខ្ញុំសរសេរគោលធម៌ខ្លីៗ ដាក់ឈ្មោះថា **ឧបករណ៍ សមថ វិបស្សនា** ហើយចាត់ការបោះពុម្ពជាកូនសៀវភៅនេះឡើង ។

ខ្ញុំសង្ឃឹមថា កូនសៀវភៅនេះ នឹងបានជាប្រយោជន៍ ដល់លោក អ្នកបដិបត្តិធម៌ និង លោក អ្នកអានខ្លះ ជាពុំខាន ។

**វត្តពោធិវង្ស** ថ្ងៃ ១៤ មេសា ព.ស. ២៥៤៦

**ភិក្ខុ ឧិន ភេន ឥន្ទប្បញ្ញោ**

www.budinst.gov.kh www.elibraryofcambodia.org

# ឧបករណ៍ សមថ វិបស្សនា

៙ ❀ ៚

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ធម៌ពួក ១

អប្បមាទ សេចក្តីមិនប្រមាទ ការមិនប្រហែសធ្វេស ជាឫសគល់ ជាទីប្រជុំចុះ នៃធម៌ជាកុសលទាំងឡាយ ។

យោនិសោមនសិការ ការគិតរាវរកដល់ឫសគល់(ហេតុ) ការគិតម៉ត់ចត់ដោយឧបាយនៃបញ្ញា ការគិតត្រូវទំនង ជាបុព្វនិមិត្តនៃអដ្ឋង្គិកមគ្គ ។

## ធម៌ពួក ២

### ធម៌ដែលត្រូវចំរើន ២ យ៉ាង

១. សមថ សេចក្តីស្ងប់ ការអប់រំចិត្តឲ្យស្ងប់

២. វិបស្សនា បញ្ញាឃើញច្បាស់ ការអប់រំចិត្តឲ្យកើតបញ្ញាឃើញច្បាស់ ។

ត្រូវចំរើន គឺ ត្រូវបដិបត្តិ ។ សេចក្តីស្ងប់ សំដៅយកសេចក្តីស្ងប់កិលេសគ្រឿងសៅហ្មងចិត្ត គឺនីវរណធម៌ ។

www.budinst.gov.kh www.elibraryofcambodia.org

ឃើញច្បាស់ មិនមែនភ្នែកមើលឃើញច្បាស់ទេ គឺបញ្ញាឃើញច្បាស់ តាមសេចក្ដីពិត ។ ការបដិបត្តិ លោកហៅថា ភាវនា ។ បដិបត្តិដើម្បីឲ្យចិត្តស្ងប់ ហៅថា សមថភាវនា បដិបត្តិដើម្បីឲ្យចិត្តកើតបញ្ញាឃើញច្បាស់ ហៅថា វិបស្សនាភាវនា ។

## ធម៌មានឧបការៈច្រើន ២ យ៉ាង

**១. សតិ** សេចក្ដីនឹករឭក ការប្រុងប្រយ័ត្ន

**២. សម្បជញ្ញៈ** សេចក្ដីដឹងខ្លួន ។

ធម៌ ២ យ៉ាងនេះ មានប្រយោជន៍ច្រើនណាស់ ត្រូវប្រើគ្រប់កិច្ចការទាំងអស់ ទាំងផ្លូវលោក ទាំងផ្លូវធម៌ ។ បើខ្វះធម៌២យ៉ាងនេះ ធ្វើអ្វីក៏មិនសម្រេចផល ប្រយោជន៍ល្អដែរ ។

## ធម៌ដែលត្រូវកំណត់ដឹង ២ យ៉ាង

**១. រូប**

**២. នាម**

រូប គឺ មហាភូតរូប ៤ និង ឧបាទាយរូប ២៤ ។ រូប គឺ ធាតុមិនដឹង ។ នាម គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ ។

www.budinst.gov.kh www.elibraryofcambodia.org

នាម គឺធាតុដឹង ។ រូប នាម កើតឡើងហើយ ប្រែប្រួល រលត់ទៅជាធម្មតា ។ ត្រូវកំណត់ដឹង គឺ ត្រូវស្គាល់វាឲ្យច្បាស់ វាកើតយ៉ាងម៉េច ? រលត់យ៉ាងម៉េច ? មានគុណ មានទោស យ៉ាងម៉េច ? គេអាចរលាស់វាចោលបានឬទេ ? ។ល។

## សង្ខារ ២ យ៉ាង

១. ឧបាទិន្នកសង្ខារ សង្ខារមានចិត្ត មានវិញ្ញាណ ឧ- មនុស្ស សត្វ ជាដើម ។

២. អនុបាទិន្នកសង្ខារ សង្ខារមិនមានចិត្ត មិនមាន វិញ្ញាណ ឧ- ផ្ទះ របស់ប្រើប្រាស់ផ្សេងៗ ជាដើម ។

សង្ខារគឺអ្វីដែលបច្ច័យប្រជុំតាក់តែង បានសេចក្ដីថា រួមផ្សំគ្នា ទើបអាចកើតឡើងបាន ។ អ្វីទាំងអស់ក្នុងលោក មិនមែនធាតុ ទោលតែមួយទេ សូម្បីក្នុងទឹក ១ ដំណក់ ក្នុងថ្ម ១ ដុំ ក៏សុទ្ធ តែរួមផ្សំគ្នាទើបអាចកើតឡើងបាន នេះជា **សង្ខារ** ។ ឯ ព្រះនិព្វាន មិនមាន បច្ច័យតាក់តែងទេជា **វិសង្ខារ** ។

## ធម៌ ២ យ៉ាង

១. សង្ខតធម៌ ធម៌ដែលមានបច្ច័យប្រជុំតាក់តែង ។

www.budinst.gov.kh www.elibraryofcambodia.org

២. **អសង្ខតធម៌** ធម៌ដែលមិនមានបច្ច័យប្រជុំតាក់តែង ។

សង្ខតធម៌ ត្រូវនៅក្រោមច្បាប់ព្រះត្រៃលក្ខណ៍ ឯអសង្ខតធម៌ គឺ ព្រះនិព្វាន មិននៅក្រោមច្បាប់ព្រះត្រៃលក្ខណ៍ទេ ប៉ុន្តែ ព្រះនិព្វានជា អនត្តា ដែរ ។

## ឈាន ២ យ៉ាង

១. **រូបឈាន**

២. **អរូបឈាន**

ការសម្លឹងអារម្មណ៍ ដោយចិត្តជា អប្បនាសមាធិ ហៅថា ឈាន ។ ការដុតកម្តៅកិលេសឲ្យក្រៀម ហៅថា ឈាន។

រូបឈាន ឈានមានរូបធម៌ជាអារម្មណ៍, ឈានជា រូបាវចរ។ អរូបឈាន ឈានមានអរូបធម៌ជាអារម្មណ៍, ឈានជា អរូបាវចរ។

រូបឈានក្តី អរូបឈានក្តី ជាពាក្យសម័យក្រោយ, ពីមុនមក គេហៅថា ឈាន និង អារុប្ប ។

## ឈាន ២ យ៉ាងទៀត

១. **អារម្មណូបនិជ្ឈាន** ការសម្លឹងអារម្មណ៍បានដល់សមាបត្តិ ៨

www.budinst.gov.kh www.elibraryofcambodia.org

គឺ រូបឈាន ៤ អរូបឈាន ៤ ។

២. **លក្ខណូបនិជ្ឈាន** ការសម្ញឹងលក្ខណៈ បានដល់ វិបស្សនា មគ្គ ផល ។

វិបស្សនា ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះពិនិត្យសង្ខារដោយព្រះត្រៃលក្ខណ៍ ។

មគ្គ ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះញុំាងកិច្ចនៃវិបស្សនាឲ្យសម្រេច ។ ផល ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះសម្ញឹងព្រះនិព្វានដែលមានលក្ខណៈ ជា សុញ្ញត អនិមិត្ត អប្បណិហិត និង ព្រោះឃើញលក្ខណៈដែលជាសច្ចភាវៈ នៃព្រះនិព្វាន ។

## វិមុត្តិ ២ យ៉ាង

១. **ចេតោវិមុត្តិ** ការរួចផុតដោយអំណាចការអប់រំចិត្ត ការរួចផុតនៃចិត្តចាករាគៈ ដោយកម្លាំងនៃសមាធិ ។

២. **បញ្ញាវិមុត្តិ** ការរួចផុតដោយអំណាចការចំរើនបញ្ញា ការរួចផុតនៃចិត្តចាកអវិជ្ជា ដោយបញ្ញាដែលឃើញតាមសេចក្តីពិត។

ការរួចផុតចាកកិលេស ដោយការបដិបត្តិ សមថ រហូតដល់បានឈានហើយបដិបត្តិ វិបស្សនា ជាខាងក្រោយរហូតដល់បាន

www.budinst.gov.kh www.elibraryofcambodia.org

សម្រេចអរហត្តផល យ៉ាងនេះ ក៏ហៅថា ចេតោវិមុត្តិ ។

ការរួចផុតចាកកិលេស ដោយការបដិបត្តិ សមថៈ តែមិនទាន់បានសម្រេចឈានទេ ហើយក៏ចាប់ បដិបត្តិ វិបស្សនា រហូតបានសម្រេច អរហត្តផល យ៉ាងនេះក៏ហៅថា បញ្ញាវិមុត្តិ។

## និព្វាន ២ យ៉ាង

១. **សឧបាទិសេសនិព្វាន** និព្វានមានឧបាទិសល់

២. **អនុបាទិសេសនិព្វាន** និព្វានមិនមានឧបាទិសល់ ។

ឧបាទិ របស់ដែលកិលេសមានឧបាទានជាដើមចូលទៅប្រកាន់មាំ គឺបញ្ចក្ខន្ធ។ រលត់កិលេស តែបញ្ចក្ខន្ធ នៅសេសសល់ ហៅថា ឧបាទិសេសនិព្វាន ឬ ហៅថា កិលេសនិព្វាន ក៏បាន។ រលត់កិលេសអស់ហើយ បញ្ចក្ខន្ធ ក៏ រលត់ទៀត យ៉ាងនេះ ហៅថាអនុបាទិសេសនិព្វាន ឬហៅថា ខន្ធនិព្វានក៏បាន ។

## ធម៌ពួក ៣

### សិក្ខា ៣ (ត្រៃសិក្ខា)

១. **សីលសិក្ខា** ឧបដិបត្តិឲ្យកើត សីល ដ៏ខ្ពង់ខ្ពស់

២. **ចិត្តសិក្ខា** ឧបដិបត្តិឲ្យកើត សមាធិ ដ៏ខ្ពង់ខ្ពស់

www.budinst.gov.kh www.elibraryofcambodia.org

៣. បញ្ញាសិក្ខា ខបដិបត្តិឲ្យកើត បញ្ញា ដ៏ខ្ពង់ខ្ពស់ ។

សិក្ខា ៣ នេះ ជួនកាលហៅថា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខាឬហៅខ្លីថា សីល សមាធិ បញ្ញា ដូចនេះក៏បាន ។

## ត្រៃលក្ខណ៍ លក្ខណៈ ៣

១. **អនិច្ចលក្ខណៈ** លក្ខណៈមិនទៀង ឬហៅថា អនិច្ចតា

២. **ទុក្ខលក្ខណៈ** លក្ខណៈជាទុក្ខ ឬហៅថា ទុក្ខតា

៣. **អនត្តលក្ខណៈ** លក្ខណៈជាអនត្តា ឬហៅថា អនត្តតា

ព្រះត្រៃលក្ខណ៍នេះ មានឈ្មោះ ហៅម្យ៉ាងទៀតថា សាមញ្ញលក្ខណៈ លក្ខណៈមានស្មើទូទៅដល់សង្ខារទាំងពួង ដូចនេះក៏បាន ។ តាមទម្លាប់គេហៅខ្លីថា អនិច្ចំ ទុក្ខំ អនត្តា ។

## សង្ខតលក្ខណៈ លក្ខណៈនៃសង្ខតធម៌ ៣

១. **ឧប្បាទោ បញ្ញាយតិ** ការកើតឡើងប្រាកដ

២. **វយោ បញ្ញាយតិ** ការសូន្យទៅប្រាកដ

៣. **ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ** កាលតាំងនៅ ការប្រែប្រួលប្រាកដ ។

www.budinst.gov.kh www.elibraryofcambodia.org

**អសង្ខតលក្ខណៈ លក្ខណៈនៃអសង្ខតធម៌ ៣**

១. **ន ឧប្បាទោ បញ្ញាយតិ** ការកើតឡើងមិនប្រាកដ
២. **ន វយោ បញ្ញាយតិ** ការសូន្យទៅមិនប្រាកដ
៣. **ន ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ** កាលតាំងនៅ ការប្រែប្រួលមិនប្រាកដ ។

**និមិត្ត ៣**

១. **បរិកម្មនិមិត្ត** គ្រឿងសំគាល់ គឺអារម្មណ៍ ដែលគេយកមកធ្វើជាទីតម្កល់នៃសតិដើម្បីទប់ចិត្តឲ្យជាសមាធិ ។
២. **ឧគ្គហនិមិត្ត** ភាពចម្លងនៃអារម្មណ៍នោះ ដែលកើតឡើងហាក់ដូចជាជាប់នៅនឹងភ្នែក ។
៣. **បដិភាគនិមិត្ត** ភាពចម្លងនៃអារម្មណ៍នោះដែរ ប៉ុន្តែ មានសភាពបរិសុទ្ធម៉ត់ចត់ជាង ហើយគេអាចពង្រីកឲ្យធំ ឬ ពង្រួញឲ្យរួមតូចក៏បាន ។

www.budinst.gov.kh www.elibraryofcambodia.org

## និមិត្ត ៣

១. សមាធិនិមិត្ត សំដៅយកចិត្តដែលផ្ដោតខ្លាំងទៅលើ
អារម្មណ៍របស់សមាធិ ។

២. បគ្គាហនិមិត្ត សំដៅយកចិត្តដែលខំប្រឹងព្យាយាមច្រើន។

៣. ឧបេក្ខានិមិត្ត សំដៅយកចិត្តដែលព្រងើយកន្តើយច្រើន។

## ភាវនា ៣

១. បរិកម្មភាវនា សំដៅយកចិត្តក្នុងខណៈចាប់បដិបត្តិ
សមាធិដំបូងៗមិនទាន់ស្ងប់ ឬស្ងប់តិចៗ។

២. ឧបចារភាវនា សំដៅយកចិត្តក្នុងខណៈដែលកើតបដិ
ភាគនិមិត្តស្ងប់ចាកនីវរណធម៌ ។ ភាវនាទាំងពីរនេះ
បដិបត្តិមកត្រឹមនេះ ចាត់ជា កាមាវចរសមាធិ ។

៣. អប្បនាភាវនា សំដៅយកចិត្តដែលឆ្លងចាកគោត្រភូខណៈ
ក្នុងឈានជវនៈ បានសម្រេច រូបជ្ឈាន អរូបជ្ឈាន ។
ភាវនានេះ ចាត់ជារូបាវចរសមាធិ អរូបាវចរសមាធិ ។

## ភាវនា ៣

| | |
|---|---|
| ១. កាយភាវនា | ការអប់រំកាយ |
| ២. ចិត្តភាវនា | ការអប់រំចិត្ត |
| ៣. បញ្ញាភាវនា | ការអប់រំបញ្ញា ។ |

www.budinst.gov.kh www.elibraryofcambodia.org

## សមាធិ ៣

១. ខណិកសមាធិ ចិត្តស្ងប់ជា ខណៈៗ គឺស្ងប់តិច ៗ

២. ឧបចារសមាធិ ចិត្តស្ងប់យូរក្រែលក្បែរៗអប្បនាសមាធិ។

៣. អប្បនាសមាធិចិត្តស្ងប់នីវរណធម៌ឬបានរូបជ្ឈានអរូបជ្ឈាន។

## សមាធិ ៣

១. សវិតក្កវិចារសមាធិ សមាធិមានវិតក្ក មានវិចារៈ

២.អវិតក្កវិចារមត្តសមាធិសមាធិមិនមានវិតក្កមានត្រឹមតែវិចារៈ

៣. អវិតក្កវិចារសមាធិ សមាធិមិនមានវិតក្ក មិនមានវិចារៈ។

## សមាធិ ៣

១. សុញ្ញតសមាធិ សមាធិមាន អនត្តា ជាអារម្មណ៍

២. អនិមិត្តសមាធិ សមាធិមាន អនិច្ចំ ជាអារម្មណ៍

៣. អប្បណិហិតសមាធិ សមាធិមាន ទុក្ខំ ជាអារម្មណ៍ ។

## វិមោក្ខ ៣

១. សុញ្ញតវិមោក្ខ ការរួចផុតព្រោះឃើញ អនត្តា

២. អនិមិត្តវិមោក្ខ ការរួចផុតព្រោះឃើញ អនិច្ចំ

៣. អប្បណិហិតវិមោក្ខ ការរួចផុតព្រោះឃើញ ទុក្ខំ ។

www.budinst.gov.kh www.elibraryofcambodia.org

## បញ្ញា ៣

១. សុតាមយបញ្ញា   បញ្ញាកើតមកអំពីការស្តាប់

២. ចិន្តាមយបញ្ញា   បញ្ញាកើតមកអំពីការគិត

៣. ភាវនាមយបញ្ញា បញ្ញាកើតមកអំពីការហ្វឹកហាត់បដិបត្តិ។

## ញាណ ៣

១. សច្ចញាណ   ញាណដឹងសច្ចទាំង ៤ គឺដឹងថា នេះទុក្ខ នេះហេតុឲ្យទុក្ខកើត នេះការរលត់ទុក្ខ នេះផ្លូវដើរទៅរកការរលត់ទុក្ខ ។

២. កិច្ចញាណ   ញាណដឹងកិច្ចដែលត្រូវធ្វើក្នុងសច្ចៈទាំង ៤ ទុក្ខ មានកិច្ចដែលគេគប្បីកំណត់ដឹង សមុទយៈមានកិច្ចដែលគេត្រូវតែលះបង់ និរោធៈ មានកិច្ចដែលគេត្រូវធ្វើឲ្យជាក់ច្បាស់ មគ្គ មានកិច្ចដែលគេត្រូវចំរើន គឺបដិបត្តិតាម ។

៣. កតញាណ   ញាណដឹងថា បានធ្វើស្រេចហើយក្នុង សច្ចៈទាំង ៤ គឺ ទុក្ខ គេបានកំណត់ដឹងហើយ សមុទយៈ គេបានលះបង់ហើយ និរោធៈ គេ បានធ្វើឲ្យជាក់ច្បាស់ហើយ

www.budinst.gov.kh   www.elibraryofcambodia.org

មគ្គ គេបានចំរើនហើយ ។

ញាណ ៣ នេះ ក្នុង អរិយសច្ច ហៅថា ញាណទស្សនៈ វិលជុំទាំង ៣ ហៅថា បរិវដ្ដៈ គ្រប់សច្ចៈទាំង ៤ត្រូវជា ១២ ហៅថា អាការៈ ។

## វិជ្ជា ៣

១. **បុព្វេនិវាសានុស្សតិញ្ញាណ** ញាណដឹងច្បាស់រឭកជាតិបាន

២. **ចុតូបបាតញ្ញាណ** ញាណដឹងច្បាស់ការច្យុតិ និងការកើតរបស់សត្វទាំងឡាយ ។

៣. **អាសវក្ខយញ្ញាណ** ញាណដឹងច្បាស់ក្នុងធម៌ជាទីអស់ទៅនៃអាសវៈ ។ វិជ្ជា៣នេះ តាមទម្លាប់ គេប្រើពាក្យថាញាណជំនួស ។

## ភព ៣

១. **កាមភព** ភពរបស់អ្នកសេពកាមគុណ ( កាមាវចរ )

២. **រូបភព** ភពរបស់អ្នកចូលដល់រូបជ្ឈាន ( រូបាវចរ )

៣. **អរូបភព** ភពរបស់អ្នកចូលដល់អរូបជ្ឈាន (អរូបាវចរ)។

www.budinst.gov.kh www.elibraryofcambodia.org

### តណ្ហា ៣

១. កាមតណ្ហា ចំណង់ក្នុងកាមគុណ

២. ភវតណ្ហា ចំណង់ក្នុងភព (ប្រកបដោយ ភវទិដ្ឋិ និង សស្សតទិដ្ឋិ ) ។

៣. វិភវតណ្ហា ចំណង់ក្នុងវិភព (ប្រកបដោយ វិភវទិដ្ឋិ និង ឧច្ឆេទទិដ្ឋិ) ។

### វដ្ដៈ ៣

១. កិលេសវដ្ដៈ គ្រឿងវិល គឺកិលេស បានដល់ អវិជ្ជា តណ្ហា ឧបាទាន

២. កម្មវដ្ដៈ គ្រឿងវិល គឺកម្ម បានដល់ សង្ខារ និងកម្មភព

៣. វិបាកវដ្ដៈ គ្រឿងវិល គឺវិបាក បានដល់ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ឧបបត្តិភព ជាតិ ជរា មរណៈ ជាដើម ។

### បបញ្ចធម៌ ៣

១. តណ្ហា ចំណង់មិនចេះចប់ គឺមិនឆ្អែត

២. ទិដ្ឋិ ជឿតែគំនិតខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

៣. **មានៈ** ប្រកាន់ថា គ្មាននរណាស្មើជាដើម ។

ធម៌ ៣ នេះ នាំឲ្យយឺតយូរ ទើបលោកហៅថា បបញ្ចធម៌។

## អបណ្ណកបដិបទា ៣

១. **ឥន្ទ្រិយសំវរៈ** សង្រួមឥន្ទ្រីយ៍ទាំង ៦ មានភ្នែកជាដើម។

២. **ភោជនេ មត្តញ្ញុតា** ស្គាល់ប្រមាណក្នុងភោជន

៣. **ជាគរិយានុយោគ** ប្រព្រឹត្តរឿយៗជាអ្នកភ្ញាក់រឭក ខំប្រឹងប្រែង ។ អបណ្ណកបដិបទា បដិបត្តិមិនខុស នរណាក៏បដិបត្តិបាន ។

## សង្ខារ ៣

១. **កាយសង្ខារ** សភាវៈតាក់តែងកាយ បានដល់អស្សាសបស្សាសៈ ខ្យល់ដកដង្ហើមចូល ដកដង្ហើមចេញ(អានាបានៈ)។

២. **វចីសង្ខារ** សភាវៈតាក់តែងវាចាបានដល់ វិតក្ក វិចារៈ។

៣. **ចិត្តសង្ខារ** សភាវៈតាក់តែងចិត្តបានដល់ សញ្ញា វេទនា។

សង្ខារ ៣ នេះគេច្រើននិយាយក្នុងរឿងសញ្ញាវេទយិតនិរោធ។

www.budinst.gov.kh www.elibraryofcambodia.org

## សង្ខារ ៣

១. កាយសង្ខារ សភាវៈតាក់តែងការធ្វើផ្លូវកាយ បានដល់កាយសញ្ចេតនា ។

២. វចីសង្ខារ សភាវៈតាក់តែងការធ្វើផ្លូវវាចា បានដល់វចីសញ្ចេតនា ។

៣. ចិត្តសង្ខារ ឬ មនោសង្ខារ សភាវៈតាក់តែងការធ្វើផ្លូវចិត្ត បានដល់ មនោសញ្ចេតនា ។

សង្ខារ ៣ នេះមានសេចក្តី ទំនាក់ទំនងនឹងពាក្យថា សង្ខារ ក្នុងបដិច្ចសមុប្បាទ ។

## អភិសង្ខារ ៣

១. បុញ្ញាភិសង្ខារ សភាវៈតាក់តែងកម្មល្អ បានដល់កុសលចេតនា ជាកាមាវចរ និងរូបាវចរ ។

២. អបុញ្ញាភិសង្ខារ សភាវៈ តាក់តែងកម្មអាក្រក់ បានដល់អកុសលចេតនាទាំងឡាយ ។

៣. អនេញ្ជាភិសង្ខារ សភាវៈតាក់តែងកម្មមិនញាប់ញ័រ បានដល់កុសលចេតនាជា អរូបាវចរ ។

www.budinst.gov.kh www.elibraryofcambodia.org

អភិសង្ខារ ៣ នេះ ជាអត្ថន័យ របស់ពាក្យ សង្ខារក្នុង បដិច្ចសមុប្បាទ ។

## វិវេក ៣

១. **កាយវិវេក** សេចក្តីស្ងប់កាយ គឺ នៅក្នុងទីស្ងាត់ម្នាក់ឯង

២. **ចិត្តវិវេក** សេចក្តីស្ងប់ចិត្ត គឺ ចិត្តស្ងប់ចាក នីវរណធម៌ សំយោជនៈ និងអនុស័យជាដើម បានដល់ចិត្តរបស់បុគ្គលដែលបានសម្រេចឈាន អរិយមគ្គ អរិយផល ។

៣. **ឧបធិវិវេក** សេចក្តីស្ងប់ចាក ឧបធិ គឺធម៌ជាទីស្ងប់រម្ងាប់នូវសង្ខារទាំងពួង ប្រាសចាកកិលេសក្តី ខន្ធក្តី អភិសង្ខារក្តី សំដៅយក ព្រះនិព្វាន ។

## វេទនា ៣

១. **សុខវេទនា** ការទទួលដឹង(សោយ) សេចក្តីសុខ

២. **ទុក្ខវេទនា** ការទទួលដឹង(សោយ) សេចក្តីទុក្ខ

៣. **អទុក្ខមសុខវេទនា** ការទទួលដឹង(សោយ) សេចក្តីមិនទុក្ខ មិនសុខ ។

www.budinst.gov.kh www.elibraryofcambodia.org

## អាសវៈ ៣

១. កាមាសវៈ អាសវៈគឺកាម សភាវៈ ដែលហូរជ្រាបចូល ទៅ ឬ ត្រាំនៅក្នុងចិត្ត ។

២. ភវាសវៈ អាសវៈគឺ ភព សភាវៈដែលហូរជ្រាបចូលទៅ ឬ ត្រាំនៅក្នុងចិត្ត ។

៣. អវិជ្ជាសវៈ អាសវៈ គឺ អវិជ្ជា សភាវៈ ដែលហូរជ្រាប ចូលទៅ ឬ ត្រាំនៅក្នុងចិត្ត ។

## និព្វាន ៣

១. កិលេសនិព្វាន រលត់កិលេស

២. ខន្ធនិព្វាន រលត់ខន្ធ

៣. ធាតុនិព្វាន រលត់ ព្រះធាតុ ។

## អគ្គិ ៣

១. រាគគ្គិ ភ្លើង គឺរាគៈ

២. ទោសគ្គិ ភ្លើង គឺទោសៈ

៣. មោហគ្គិ ភ្លើង គឺ មោហៈ ។

www.budinst.gov.kh www.elibraryofcambodia.org

### ធាតុ ៣

១. រូបធាតុ ធាតុ គឺ អ្វីដែលចាត់ជា រូប

២. អរូបធាតុ ធាតុ គឺ អ្វីដែលមិនចាត់ជារូប គឺ នាម

៣. និរោធធាតុ ធាតុ គឺ ការរលត់ មិនមែនជារូប មិនមែនជានាម គឺ ព្រះនិព្វន។

## ធម៌ពួក ៤

### ធាតុ ៤

១. បឋវីធាតុ ធាតុដី

២. អាបោធាតុ ធាតុទឹក

៣. តេជោធាតុ ធាតុភ្លើង

៤. វាយោធាតុ ធាតុខ្យល់

ធាតុ ៤នេះជួនកាល គេហៅថា មហាភូតរូប រូបធំៗ ជាទីប្រជុំ ជាមេនៃវត្ថុធាតុទាំងឡាយ នេះជាធាតុ ៤ ខាងក្រៅ។ ចំណែក រូបកាយយើង ក៏ជាធាតុ ៤ដែរ ប៉ុន្តែជាធាតុខាងក្នុង។

www.budinst.gov.kh www.elibraryofcambodia.org

## សតិប្បដ្ឋាន ៤

ធម៌ជាទីតាំងនៃសតិ ដើម្បីទប់ចិត្តឲ្យនៅនឹងមួយកន្លែងហើយពិចារណាឲ្យឃើញនូវធម៌នោះតាមសេចក្ដីពិត កំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស មិនមានតណ្ហា ឧបាទាន ក្នុងអ្វីៗទាំងអស់ ។ ធម៌នោះ ហៅថា សតិប្បដ្ឋាន មាន ៤ គឺ

១. **កាយ** ឬ ហៅថា កាយានុបស្សនាសតិប្បដ្ឋាន

២. **វេទនា** ឬ ហៅថា វេទនានុបស្សនាសតិប្បដ្ឋាន

៣. **ចិត្ត** ឬ ហៅថា ចិត្តានុបស្សនាសតិប្បដ្ឋាន

៤. **ធម៌** ឬ ហៅថា ធម្មានុបស្សនាសតិប្បដ្ឋាន ។

ពាក្យថា កាយ ចែកចេញជា ៦ គឺ ១.អានាបានៈ ខ្យល់ដង្ហើមចេញ ចូល ២. ឥរិយាបថៈ ឥរិយាបថ ៤ ដើរ ឈរ អង្គុយ ដេក ៣. សម្បជញ្ញៈ មានសតិសម្បជញ្ញៈដឹងទាន់គ្រប់សកម្មភាពឈានទៅមុខ ថយក្រោយ ងាកស្ដាំ ងាកឆ្វេងជាដើម ៤. បដិក្កូល ពិចារណារូបកាយ សក់ រោម ក្រចក ធ្មេញ ស្បែក ជាដើមឲ្យឃើញ ជាបដិក្កូលគួរខ្ពើម ៥. ធាតុ ពិចារណារូបកាយឲ្យឃើញជាធាតុ៤ ៦. នវសីវថិកា ពិចារណាសាកសព ៩ បែប ។

www.budinst.gov.kh www.elibraryofcambodia.org

វេទនា ចែកចេញជា ៣ គឺ សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា ប្រកបដោយអាមិសក្តី មិនប្រកបដោយអាមិសក្តី ។

ចិត្ត ចែកចេញជា ១៦ គឺ ចិត្តមានរាគៈ(សរាគៈ) ចិត្តមិនមានរាគៈ (វីតរាគៈ) ចិត្តមានទោសៈ ចិត្តមិនមានទោសៈ ចិត្តមានមោហៈ ចិត្តមិនមានមោហៈ ចិត្តរួញរា(សង្ខិត្ត) ចិត្តរាយមាយ (វិក្ខិត្ត) ចិត្តដល់នូវភាពជាធំ (មហគ្គតៈ) ចិត្តមិនដល់នូវភាពជាធំ(អមហគ្គត)ចិត្តនៅមានចិត្តដទៃប្រសើរជាង(សឧត្តរ) ចិត្តមិនមានចិត្តដទៃប្រសើរជាង (អនុត្តរ) ចិត្តតាំងនៅមាំ (សមាហិត) ចិត្តមិនតាំងនៅមាំ (អសមាហិត) ចិត្តរួចផុត (វិមុត្ត) ចិត្តមិនទាន់រួចផុត (អវិមុត្ត) ។

ធម៌. ចែកចេញជា ៥ គឺ នីវរណៈ៥ ខន្ធ ៥ អាយតនៈ ១២ ពោជ្ឈង្គ ៧ សច្ចៈ ៤ ។

**សម្មប្បធាន ៤**

១. **សំវរបធាន** ព្យាយាមបិទទប់បាបអកុសល ដែលមិនទាន់កើតមិនឲ្យកើតឡើងបាន ។

២. **បហានបធាន** ព្យាយាមលះបាបអកុសលដែលកើតឡើងហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

៣. **ភាវនាបធាន** ព្យាយាមចំរើនបុណ្យកុសល ដែលមិនទាន់កើត ឲ្យកើតឡើង ។

៤. **អនុរក្ខនាបធាន** ព្យាយាមថែរក្សាបុណ្យកុសល ដែលកើតឡើងហើយឲ្យតាំងនៅមាំ និងធ្វើឲ្យរីកតែរីកចំរើនឡើងជាភិយ្យោភាពទៀត ។

បធាន សម្មប្បធាន និង សម្មាវាយាម ប្រើជំនួសគ្នាបាន ។

## ឥទ្ធិបាទ ៤

១. **ឆន្ទៈ** សេចក្តីពេញចិត្ត បំណង

២. **វីរិយៈ** សេចក្តីព្យាយាម

៣. **ចិត្ត** ការយកចិត្តទុកដាក់ គំនិត

៤. **វិមំសា** ការត្រិះរិះ ពិចារណា ។

ឥទ្ធិបាទទាំង ៤ នេះ ជាធម៌នាំឲ្យសម្រេចកិច្ចការផ្សេងៗ បើកិច្ចការនោះមិនហួសវិស័យទេ ។ ចំពោះអ្នកបដិបត្តិធម៌ ព្រះពុទ្ធប្រៀនប្រដៅឲ្យចំរើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និង បធានសង្ខារ ប្រកបដោយវីរិយសមាធិ និង បធានសង្ខារ ប្រកបដោយចិត្តសមាធិ... ប្រកបដោយវិមំសាសមាធិ និង បធានសង្ខារ ។

www.budinst.gov.kh www.elibraryofcambodia.org

ឱឃៈ ៤

១. កាមោឃៈ អន្លង់ គឺ កាម

២. ភវោឃៈ អន្លង់ គឺ ភព

៣. ទិដ្ឋោឃៈ អន្លង់ គឺ ទិដ្ឋិ

៤. អវិជ្ជោឃៈ អន្លង់ គឺ អវិជ្ជា

អាសវៈ ៤

១. កាមាសវៈ អាសវៈ គឺកាម

២. ភវាសវៈ អាសវៈ គឺភព

៣. ទិដ្ឋាសវៈ អាសវៈ គឺទិដ្ឋិ

៤. អវិជ្ជាសវៈ អាសវៈ គឺអវិជ្ជា

បើសង្គ្រោះត្រឹម ៣ ទិដ្ឋាសវៈ ចូលជាមួយ ភវាសវៈ ។

ឧបាទាន ៤

១. កាមុបាទាន ប្រកាន់មាំក្នុងកាម

២. ទិដ្ឋុបាទាន ប្រកាន់មាំក្នុងទិដ្ឋិ

៣. សីលព្វតុបាទាន ប្រកាន់មាំក្នុងសីល និងវត្ត ព្រមទាំងប្រពៃណីផ្សេងៗ និង វត្ថុសក្តិសិទ្ធិខ្លាំងពូកែ ។

៤. អត្តវាទុបាទាន ប្រកាន់មាំក្នុងវាទៈថា មានខ្លួន ។

www.budinst.gov.kh www.elibraryofcambodia.org

## ព្រហ្មវិហារ ៤

១. មេត្តា សេចក្តីស្រឡាញ់រាប់អាន

២. ករុណា សេចក្តីអាណិតអាសូរ

៣. មុទិតា សេចក្តីរីករាយជាមួយនឹងសេចក្តីល្អរបស់អ្នកដទៃ

៤. ឧបេក្ខា ការតាំងចិត្តជាកណ្តាល ។

បើផ្សាយទៅដោយមិនមានព្រំដែនហៅថា អប្បមញ្ញា ។

## បរមត្ថធម៌ ៤

១. ចិត្ត សភាវៈដឹងអារម្មណ៍

២. ចេតសិក សភាវៈប្រកបជាមួយចិត្ត

៣. រូប សភាវៈជារូបមិនដឹងអារម្មណ៍

៤. និព្វាន សភាវៈដែលអស់កិលេសនិងទុក្ខ ។

## អវិជ្ជា ៤

១. ទុក្ខេ អញ្ញាណំ មិនដឹងច្បាស់ទុក្ខ

២. ទុក្ខសមុទយេ អញ្ញាណំ មិនដឹងច្បាស់ហេតុឲ្យទុក្ខកើត។

៣. ទុក្ខនិរោធេ អញ្ញាណំ មិនដឹងច្បាស់ការរលត់ទុក្ខ

៤. ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ មិនដឹងច្បាស់បដិបទាឲ្យដល់នូវការរលត់ទុក្ខ។

www.budinst.gov.kh www.elibraryofcambodia.org

## ភាវនា ៤

១. កាយភាវនា ចំរើនកាយ

២. សីលភាវនា ចំរើនសីល

៣. ចិត្តភាវនា ចំរើនចិត្ត

៤. បញ្ញាភាវនា ចំរើនបញ្ញា ។

## បដិបទា ៤

១.ទុក្ខាបដិបទា ទន្ធាភិញ្ញា បដិបត្តិពិបាក ត្រាស់ដឹងយឺតយូរ

២.ទុក្ខាបដិបទា ខិប្បាភិញ្ញា បដិបត្តិពិបាក ត្រាស់ដឹងឆាប់

៣.សុខាបដិបទា ទន្ធាភិញ្ញា បដិបត្តិស្រួល ត្រាស់ដឹងយឺតយូរ

៤.សុខាបដិបទា ខិប្បាភិញ្ញា បដិបត្តិស្រួល ត្រាស់ដឹងឆាប់។

## បដិបទា ៤

១. អក្ខមា បដិបទា បដិបត្តិមិនអត់ធន់

២. ខមា បដិបទា បដិបត្តិអត់ធន់

៣. ទមា បដិបទា បដិបត្តិទូន្មាន

៤. សមា បដិបទា បដិបត្តិស្ងប់រម្ងាប់ ។

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

## សង្ខារ ៤

១. សង្ខតសង្ខារ សង្ខារកើតចាកបច្ច័យតាក់តែង

២. អភិសង្ខតសង្ខារ សង្ខារកើតពីកម្មតាក់តែង

៣. អភិសង្ខរណកសង្ខារ សង្ខារគឺកម្មដែលជាតួតាក់តែង

៤. បយោគាភិសង្ខារ សង្ខារគឺការប្រកបសេចក្តីព្យាយាម។

## សម្បជញ្ញៈ ៤

១. សាត្ថកសម្បជញ្ញៈ ដឹងច្បាស់ថាមានប្រយោជន៍

២.សប្បាយសម្បជញ្ញៈ ដឹងច្បាស់ថាសប្បាយគឺគួរសមដល់ខ្លួន

៣. គោចរសម្បជញ្ញៈ ដឹងច្បាស់ថាជាគោចរគឺការងាររបស់ខ្លួន

៤. អសម្មោហសម្បជញ្ញៈ ដឹងច្បាស់ថាមិនវង្វេង ។

## ចតុប្បារិសុទ្ធិសីល ៤

១. បាដិមោក្ខសំវរសីល សីលគឺការសង្រួមក្នុងបាដិមោក្ខ

២. ឥន្ទ្រិយសំវរសីល សីលគឺការសង្រួមឥន្ទ្រីយ៍

៣. អាជីវបារិសុទ្ធិសីល សីលគឺការបរិសុទ្ធិនៃអាជីវៈ

៤. បច្ចយសន្និស្សិតសីល សីលអាស្រ័យការប្រើប្រាស់បច្ច័យ
ដោយបាន ពិចារណា ។

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE



## រូបជ្ឈាន ៤

១. **បឋមជ្ឈាន** មានអង្គ ៥ គឺ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា

២. **ទុតិយជ្ឈាន** មានអង្គ ៣ គឺ បីតិ សុខ ឯកគ្គតា

៣. **តតិយជ្ឈាន** មានអង្គ ២ គឺ សុខ ឯកគ្គតា

៤. **ចតុត្ថជ្ឈាន** មានអង្គ ២ គឺ ឧបេក្ខា ឯកគ្គតា ។

ឈាន ៤ នេះ គម្ពីរអភិធម្មចែកជា ៥ ដោយចែកបឋមជ្ឈានជាពីរ ព្រោះអ្នកបញ្ញាខ្សោយ លះអង្គឈានបានម្តងតែមួយប៉ុណ្ណោះ ។ ឈាន ៤ ឈ្មោះថា ចតុក្កន័យ ឈាន ៥ ឈ្មោះថាបញ្ចក្កន័យ ។

## អរូបជ្ឈាន ៤

១. **អាកាសានញ្ចាយតន** កំណត់អាកាសជាអារម្មណ៍

២. **វិញ្ញាណញ្ចាយតន** កំណត់វិញ្ញាណជាអារម្មណ៍

៣. **អាកិញ្ចញ្ញាយតន** កំណត់ភាវៈមិនមានអ្វីជាអារម្មណ៍

៤. **នេវសញ្ញានាសញ្ញាយតន** មានសញ្ញាជាអារម្មណ៍ក៏មិនមែន មិនមានសញ្ញាជាអារម្មណ៍ក៏មិនមែន ។

www.budinst.gov.kh www.elibraryofcambodia.org

## សមាធិ ៤

១. ហានភាគិយសមាធិ សមាធិមានចំណែកសាបសូន្យ

២. ឋិតិភាគិយសមាធិ សមាធិមានចំណែកតាំងនៅ

៣. វិសេសភាគិយសមាធិ សមាធិមានចំណែកវិសេស

៤. និព្វេធភាគិយសមាធិ សមាធិមានចំណែកចាក់ធ្លុះ ។

## អរិយសច្ច ៤

១. ទុក្ខសច្ច ជាតិ ជរា មរណៈ

២. សមុទយសច្ច តណ្ហា ៣

៣. និរោធសច្ច និព្វាន

៤. មគ្គសច្ច មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ។

## មគ្គ ៤

១. សោតាបត្តិមគ្គ

២. សកទាគាមិមគ្គ

៣. អនាគាមិមគ្គ

៤. អរហត្តមគ្គ

មគ្គក្នុងទីនេះ សំដៅយកបញ្ញាដែលកើតពីការឃើញមគ្គអាចកំចាត់សំយោជនកិលេស ជាសមុច្ឆេទប្បហានបាន ។

www.budinst.gov.kh www.elibraryofcambodia.org

ផល ៤

១. សោតាបត្តិផល

២. សកទាគាមិផល

៣. អនាគាមិផល

៤. អរហត្តផល

ផលក្នុងទីនេះ ជាធម្មារម្មណ៍ដែលព្រះអរិយបុគ្គល គប្បីសោយ ជាផលកើតឯងក្នុងកាលដែលលះកិលេសអស់ដោយអំណាចមគ្គនោះ ។

ផលនៃសមាធិភាវនា ៤

១. ទិដ្ឋធម្មសុខវិហារ ដើម្បីសេចក្តីសុខក្នុងបច្ចុប្បន្ន

២. ញាណទស្សន ដើម្បីបានញាណទស្សនៈ

៣. សតិសម្បជញ្ញ ដើម្បីបានសតិសម្បជញ្ញៈ

៤. អាសវក្ខយ ដើម្បីអស់អាសវៈ

ធម៌ពួក ៥

ខន្ធ ៥

១. រូប រូបធាតុ ឬ ធាតុមិនដឹង

២. វេទនា សភាវៈមិនមានរូប តែដឹង សុខ ទុក្ខ

៣. សញ្ញា សភាវៈមិនមានរូប តែដឹងកត់ចំណាំ

www.budinst.gov.kh www.elibraryofcambodia.org

៤. សង្ខារ សភាវៈមិនមានរូប តែដឹងគិតគូរ

៥. វិញ្ញាណ សភាវៈមិនមានរូប តែដឹង ឃើញ ឮជាដើម។

ខន្ធ ៥ នេះ បង្រួមឲ្យខ្លីមានតែ ២ គឺ រូប នាម ។ រូបគឺ រូប ។ វេទនា សញ្ញា សង្ខារ វិញ្ញាណ ជានាម គឺមានតែឈ្មោះ និង ការដឹងអារម្មណ៍តែប៉ុណ្ណោះ ។ មនុស្សយើង គឺខន្ធ ៥ នេះឯង ។ ក្នុងត្រៃលោក មានតែរូបនាមប៉ុណ្ណោះ ។

## ឧបាទានក្ខន្ធ ៥

១. រូបុបាទានក្ខន្ធ សេចក្តីប្រកាន់មាំក្នុងរូប

២. វេទនុបាទានក្ខន្ធ សេចក្តីប្រកាន់មាំក្នុងវេទនា

៣. សញ្ញុបាទានក្ខន្ធ សេចក្តីប្រកាន់មាំក្នុងសញ្ញា

៤. សង្ខារុបាទានក្ខន្ធ សេចក្តីប្រកាន់មាំក្នុងសង្ខារ

៥. វិញ្ញាណុបាទានក្ខន្ធ សេចក្តីប្រកាន់មាំក្នុងវិញ្ញាណ។

## កាមគុណ ៥

១. រូប ជាទីស្រឡាញ់ ជាទីគាប់ចិត្ត

២. សម្លេង ជាទីស្រឡាញ់ ជាទីគាប់ចិត្ត

៣. ក្លិន ជាទីស្រឡាញ់ ជាទីគាប់ចិត្ត

www.budinst.gov.kh www.elibraryofcambodia.org

៤. រស ជាទីស្រឡាញ់ ជាទីគាប់ចិត្ត

៥. ផោដ្ឋព្វៈ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ។

## នីវរណៈ ៥

ធម៌ជាគ្រឿងរាំងមិនឲ្យចំរើន មិនឲ្យស្ងប់ មិនឲ្យកើតបញ្ញា ហៅថា នីវរណៈ មាន ៥គឺៈ

១. កាមច្ឆន្ទ សេចក្តីពេញចិត្តក្នុងកាម

២. ព្យាបាទ គំនុំ ឬ សេចក្តីប្រទូស្តរ៉ាយ

៣. ថីនមិទ្ធ សេចក្តីធុញទ្រាន់ ងោកងុយ

៤. ឧទ្ធច្ចកុក្កុច្ច សេចក្តីអណ្តែតអណ្តូង (រាយមាយ) រសាប់រសល់

៥. វិចិកិច្ឆា សេចក្តីសង្ស័យ ។

## ឧបមានីវរណៈ ៥

១. កាមច្ឆន្ទ ប្រៀបដូច ទឹកមានពណ៌ផ្សេង ៗ

២. ព្យាបាទ ប្រៀបដូច ទឹកពុះ

៣. ថីនមិទ្ធ ប្រៀបដូច ទឹកមានចកសារ៉ាយ

៤. ឧទ្ធច្ចកុក្កុច្ច ប្រៀបដូច ទឹករលក

៥. វិចិកិច្ឆា ប្រៀបដូច ទឹកល្អក់ ។

www.budinst.gov.kh www.elibraryofcambodia.org

## ឧបមានីវរណៈ ៥

| | | |
|---|---|---|
| ១. កាមច្ឆន្ទ | ប្រៀបដូច | បំណុល |
| ២. ព្យាបាទ | ប្រៀបដូច | រោគ |
| ៣. ថីនមិទ្ធ | ប្រៀបដូច | គុក |
| ៤. ឧទ្ធច្ចកុក្កុច្ច | ប្រៀបដូច | ទាសៈ |
| ៥. វិចិកិច្ឆា | ប្រៀបដូច | ផ្លូវឆ្ងាយ ។ |

## អាហាររបស់នីវរណៈ ៥

១. សុភនិមិត្ត ការកំណត់ថា ល្អ ថាស្អាត ជាអាហាររបស់ កាមច្ឆន្ទ

២. បដិឃៈ ការទើសចិត្ត ជាអាហាររបស់ ព្យាបាទ

៣. អរតិ សេចក្តីមិនត្រេកអរ តន្ទិ សេចក្តីខ្ជិល ភត្តសម្មទ ការពុលបាយ ជាអាហាររបស់ ថីនមិទ្ធ

៤. ចេតសោ អវូបសម ការមិនចូលទៅស្ងប់រម្ងាប់ចិត្ត ជាអាហាររបស់ ឧទ្ធច្ចកុក្កុច្ច

៥. អយោនិសោមនសិការ ការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ជាអាហាររបស់ វិចិកិច្ឆា ។

www.budinst.gov.kh www.elibraryofcambodia.org

## ធម៌កំចាត់នីវរណៈ ៥

១. អសុភនិមិត្ត ការកំណត់ថា មិនល្អ មិនស្អាត កំចាត់ កាមច្ឆន្ទៈ

២. មេត្តា សេចក្ដីស្រឡាញ់រាប់អាន កំចាត់ ព្យាបាទ

៣. អារម្ភធាតុ ធាតុផ្ដួចផ្ដើម និក្កមធាតុ ធាតុព្យាយាម បរក្កមធាតុ ធាតុប្រឹងប្រែង កំចាត់ ថីនមិទ្ធៈ

៤. ចេតសោវូបសម ការចូលទៅស្ងប់រម្ងាប់ចិត្ត កំចាត់ ឧទ្ធច្ចកុក្កុច្ច

៥. យោនិសោមនសិការ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា កំចាត់ វិចិកិច្ឆា ។

## អង្គឈានកំចាត់នីវរណៈ ៥

១. វិតក្ក កំចាត់ ថីនមិទ្ធៈ

២. វិចារៈ កំចាត់ វិចិកិច្ឆា

៣. បីតិ កំចាត់ ព្យាបាទ

៤. សុខៈ កំចាត់ ឧទ្ធច្ចកុក្កុច្ច

៥. ឯកគ្គតា (សមាធិ) កំចាត់ កាមច្ឆន្ទ

www.budinst.gov.kh www.elibraryofcambodia.org

## ឱរម្ភាគិយសំយោជនៈ ៥

១. សក្កាយទិដ្ឋិ សេចក្តីយល់ឃើញថាជាកាយរបស់ខ្លួន

២. វិចិកិច្ឆា សេចក្តីសង្ស័យ

៣. សីលព្វតុបរាមាស ការប្រកាន់មាំក្នុងសីលនិងវត្តព្រមទាំងពិធីផ្សេង ៗ ជាដើម

៤. កាមច្ឆន្ទ សេចក្តីពេញចិត្តក្នុងកាម

៥. ព្យាបាទ គំនុំ សេចក្តីប្រទូស្តរ៉ាយ ។

## ឧទ្ធម្ភាគិយសំយោជនៈ ៥

១. រូបរាគ សេចក្តីត្រេកអរក្នុងរូប

២. អរូបរាគ សេចក្តីត្រេកអរក្នុងអរូប

៣. មានៈ សេចក្តីប្រកាន់

៤. ឧទ្ធច្ចៈ សេចក្តីរាយមាយ

៥. អវិជ្ជា សេចក្តីមិនដឹង

គួរកត់ចំណាំ គេអាចប្រើ កាមរាគ ជំនួស កាមច្ឆន្ទ បដិឃ ជំនួស ព្យាបាទ ។ និងមានរៀបរាប់ខុសពីនេះខ្លះទៀតក៏មាន ។

www.budinst.gov.kh www.elibraryofcambodia.org

## បីតិ ៥

១. ខុទ្ទកាបីតិ សេចក្តីឆ្អែតចិត្តតិចៗធ្វើឲ្យព្រឺរោម ឬឲ្យចេញទឹកភ្នែក ។

២. ខណិកាបីតិ សេចក្តីឆ្អែតចិត្តជាខណៈៗព្រឺរោមខ្វាកៗដូចផ្លេកបន្ទោរ ។

៣. ឱក្កន្តិកាបីតិ សេចក្តីឆ្អែតចិត្តប៉ះម្តងៗ ដូចរលកផ្ទប់ច្រាំង។

៤. ឧព្វេង្គាបីតិ សេចក្តីឆ្អែតចិត្តធ្វើឲ្យហាក់ដូចជាអណ្តែតខ្លួន ឬអាចបញ្ចេញអាកប្បកិរិយាឬបញ្ចេញវាចាដោយឥតមានចេតនា។

៥. ផរណាបីតិ សេចក្តីឆ្អែតចិត្តធ្វើឲ្យស្រួលជ្រួតជ្រាបសព្វសព៌ាង្គកាយ ។

## ឥន្ទ្រីយ ៥

១. សទ្ធិន្ទ្រីយ សទ្ធា ជាធំក្នុងជំនឿ

២. វីរិយិន្ទ្រីយ វីរិយ ជាធំក្នុងសេចក្តីព្យាយាម

៣. សតិន្ទ្រីយ សតិ ជាធំក្នុងការនឹករឭក

៤. សមាធិន្ទ្រីយ សមាធិ ជាធំក្នុងការតាំងចិត្តមាំ

៥. បញ្ញិន្ទ្រីយ បញ្ញា ជាធំក្នុងសេចក្តីដឹងច្បាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

## ពលៈ ៥

១. សទ្ធាពល សទ្ធា ជាកម្លាំងក្នុងជំនឿ

២. វីរិយពល វីរិយៈ ជាកម្លាំងក្នុងសេចក្ដីព្យាយាម

៣. សតិពល សតិ ជាកម្លាំងក្នុងការកំចាត់សេចក្ដីភាយមាយ

៤. សមាធិពល សមាធិ ជាកម្លាំងក្នុងការតាំងចិត្តមាំ

៥. បញ្ញាពល បញ្ញា ជាកម្លាំងក្នុងការដឹងច្បាស់ ។

## វិមុត្តិ ៥

១. វិក្ខម្ភនវិមុត្តិ រួចផុតចាកនីវរណៈដោយការចូលឈាន

២. តទង្គវិមុត្តិ រួចផុតចាកកិលេសនោះៗដោយអង្គធម៌ដែលផ្ទុយគ្នា ។

៣. សមុច្ឆេទវិមុត្តិ រួចផុតចាកកិលេសដោយមគ្គញាណ (លោកុត្តរមគ្គ)

៤. បដិបស្សទ្ធិវិមុត្តិ រួចផុតចាកកិលេសក្នុងខណៈផលញាណ (លោកុត្តរផល) ។

៥. និស្សរណវិមុត្តិ រួចផុតចាកកិលេសក្នុងខណៈបន្ទាប់ពីផលញាណរៀងរហូតទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

## ធម៌ពួក ៦

### ចរិត ៦

១. រាគចរិត ប្រព្រឹត្តទៅតាមរាគៈ ចូលចិត្តស្អាត

២. ទោសចរិត ប្រព្រឹត្តទៅតាមទោសៈឆាប់ខឹង

៣. មោហចរិត ប្រព្រឹត្តទៅតាមមោហៈ ច្រើនភ្លេច

៤. សទ្ធាចរិត ប្រព្រឹត្តទៅតាមសទ្ធា ច្រើនឆាប់ជឿ

៥. ពុទ្ធិចរិត ប្រព្រឹត្តទៅតាមបញ្ញា គិតច្រើន ច្រើនជឿខ្លួនឯង

៦.វិតក្កចរិតប្រព្រឹត្តទៅតាមវិតក្ក ត្រិះរិះច្រើន ច្រើនរាយមាយ។

### អាយតនៈខាងក្នុង ៦

១. ចក្ខុ ភ្នែក

២. សោត ត្រចៀក

៣. ឃាន ច្រមុះ

៤. ជិវ្ហា អណ្តាត

៥. កាយ កាយ

៦. មនះ ចិត្ត ។

www.budinst.gov.kh www.elibraryofcambodia.org

## អាយតនខាងក្រៅ ៦

| | |
|---|---|
| ១. រូប | រូប |
| ២. សទ្ទ | សម្លេង |
| ៣.. គន្ធ | ក្លិន |
| ៤. រស | រស |
| ៥. ផោដ្ឋព្វ | វត្ថុដែលប៉ះកាយ |
| ៦. ធម្ម ឬ ធម្មារម្មណ៍ | អារម្មណ៍គឺធម៌ដែលប៉ះចិត្ត។ |

## វិញ្ញាណ ៦

| | |
|---|---|
| ១. ចក្ខុវិញ្ញាណ | សេចក្តីដឹងអារម្មណ៍ផ្លូវភ្នែក |
| ២. សោតវិញ្ញាណ | សេចក្តីដឹងអារម្មណ៍ផ្លូវត្រចៀក |
| ៣. ឃានវិញ្ញាណ | សេចក្តីដឹងអារម្មណ៍ផ្លូវច្រមុះ |
| ៤. ជីវ្ហាវិញ្ញាណ | សេចក្តីដឹងអារម្មណ៍ផ្លូវអណ្តាត |
| ៥. កាយវិញ្ញាណ | សេចក្តីដឹងអារម្មណ៍ផ្លូវកាយ |
| ៦. មនោវិញ្ញាណ | សេចក្តីដឹងអារម្មណ៍ផ្លូវចិត្ត ។ |

www.budinst.gov.kh www.elibraryofcambodia.org

## ផស្សៈ ឬ សម្ផស្ស ៦

១. ចក្ខុសម្ផស្ស ការជួបជុំនៃធម៌ ៣ គឺ ភ្នែករូបចក្ខុវិញ្ញាណ
២. សោតសម្ផស្ស ការជួបជុំនៃធម៌ ៣ គឺ ត្រចៀកសម្លេង សោតវិញ្ញាណ
៣. ឃានសម្ផស្ស ការជួបជុំនៃធម៌៣គឺច្រមុះក្លិនឃានវិញ្ញាណ
៤. ជិវ្ហាសម្ផស្ស ការជួបជុំនៃធម៌៣ គឺអណ្តាតរសជិវ្ហាវិញ្ញាណ
៥. កាយសម្ផស្ស ការជួបជុំនៃធម៌ ៣ គឺ កាយផោដ្ឋព្វកាយ-វិញ្ញាណ
៦. មនោសម្ផស្ស ការជួបជុំនៃធម៌៣ គឺចិត្តធម្មមនោវិញ្ញាណ។

## វេទនា ៦

១. ចក្ខុសម្ផស្សជា វេទនា វេទនាកើតពី ចក្ខុសម្ផស្ស
២. សោតសម្ផស្សជា វេទនា វេទនាកើតពី សោតសម្ផស្ស
៣. ឃានសម្ផស្សជា វេទនា វេទនាកើតពី ឃានសម្ផស្ស
៤. ជិវ្ហាសម្ផស្សជា វេទនា វេទនាកើតពី ជិវ្ហាសម្ផស្ស
៥. កាយសម្ផស្សជា វេទនា វេទនាកើតពី កាយសម្ផស្ស
៦. មនោសម្ផស្សជា វេទនា វេទនាកើតពី មនោសម្ផស្ស

www.budinst.gov.kh www.elibraryofcambodia.org

## សញ្ញា ៦

១. រូបសញ្ញា ចំណាំរូប ខ្មៅ ស..

២. សទ្ទសញ្ញា ចំណាំសម្លេង គ្រលរ គ្រលួច

៣. គន្ធសញ្ញា ចំណាំក្លិន ក្រអូប ស្អុយ

៤. រសសញ្ញា ចំណាំរស ផ្អែម ជូរ

៥. ផោដ្ឋព្វសញ្ញា ចំណាំផោដ្ឋព្វៈ រឹង ទន់

៦. ធម្មសញ្ញា ចំណាំធម៌ គួរស្រឡាញ់ ស្អប់ទៀងមិនទៀង ។

## សញ្ចេតនា(ចេតនា) ៦

១. រូបសញ្ចេតនា តាំងចិត្ត ឬ ផ្តោតចិត្តក្នុងរូប

២. សទ្ទសញ្ចេតនា តាំងចិត្ត ឬ ផ្តោតចិត្តក្នុងសម្លេង

៣. គន្ធសញ្ចេតនា តាំងចិត្ត ឬ ផ្តោតចិត្តក្នុងក្លិន

៤. រសសញ្ចេតនា តាំងចិត្ត ឬ ផ្តោតចិត្តក្នុងរស

៥. ផោដ្ឋព្វសញ្ចេតនា តាំងចិត្ត ឬ ផ្តោតចិត្តក្នុងផោដ្ឋព្វៈ

៦. ធម្មសញ្ចេតនា តាំងចិត្ត ឬ ផ្តោតចិត្តក្នុងធម្មារម្មណ៍

## តណ្ហា ៦

១. រូបតណ្ហា ចំណង់ក្នុងរូប

www.budinst.gov.kh www.elibraryofcambodia.org

២. សទ្ទតណ្ហា ចំណង់ក្នុងសម្លេង
៣. គន្ធតណ្ហា ចំណង់ក្នុងក្លិន
៤. រសតណ្ហា ចំណង់ក្នុងរស
៥. ផោដ្ឋព្វតណ្ហា ចំណង់ក្នុងផោដ្ឋព្វៈ
៦. ធម្មតណ្ហា ចំណង់ក្នុងធម្មារម្មណ៍ ។

## អភិញ្ញា ៦

១. ឥទ្ធិវិធិ សំដែង ឫទ្ធិផ្សេងៗបាន
២. ទិព្វសោត ត្រចៀកទិព្វ
៣. ចេតោបរិយញ្ញាណ ដឹងចិត្តអ្នកដទៃ
៤. បុព្វេនិវាសានុស្សតិ រឭកជាតិបាន
៥. ទិព្វចក្ខុ (ចុតូបបាតញាណ) ភ្នែកទិព្វ
៦. អាសវក្ខយញ្ញាណ អស់អាសវៈ ។

## សតតវិហារ ៦

១. ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ
ន ទុម្មនោ ឧបេក្ខកោ ច វិហរតិ សតោ

www.budinst.gov.kh www.elibraryofcambodia.org

សម្បជានោ ឃើញរូបដោយភ្នែក មិនសោមនស្ស មិនទោមនស្ស តាំងចិត្តជាកណ្តាល មានសតិ សម្បជញ្ញ ។

២. ឮសម្លេងដោយត្រចៀក មិនសោមនស្ស មិនទោមនស្ស តាំងចិត្តជាកណ្តាល មានសតិ សម្បជញ្ញ ។

៣. ធុំក្លិនដោយច្រមុះ មិនសោមនស្ស មិនទោមនស្ស តាំងចិត្តជាកណ្តាល មានសតិ សម្បជញ្ញ ។

៤. ភ្លក់រសជាតិដោយអណ្តាត មិនសោមនស្ស មិនទោមនស្ស តាំងចិត្តជាកណ្តាល មានសតិ សម្បជញ្ញ ។

៥. ប៉ះផោដ្ឋព្វៈដោយកាយ មិនសោមនស្ស មិនទោមនស្ស តាំងចិត្តជាកណ្តាល មានសតិ សម្បជញ្ញ ។

៦. ដឹងធម្មារម្មណ៍ដោយចិត្ត មិនសោមនស្ស មិនទោមនស្ស តាំងចិត្តជាកណ្តាល មានសតិ សម្បជញ្ញ ។

## ធម៌ពួក ៧

## អរិយទ្រព្យ ៧

១. **សទ្ធាធន** ទ្រព្យ គឺ សទ្ធា

២. **សីលធន** ទ្រព្យ គឺ សីល

៣. **ហិរិធន** ទ្រព្យ គឺ សេចក្តីខ្មាសបាប

www.budinst.gov.kh www.elibraryofcambodia.org

៤. ឱត្តប្បធន ទ្រព្យ គឺ សេចក្ដីខ្លាចបាប

៥. សុតធន ទ្រព្យ គឺ ការស្ដាប់

៦.ចាគធន ទ្រព្យ គឺ ការលះ

៧. បញ្ញាធន ទ្រព្យ គឺ បញ្ញា ។

## ពលៈ ៧

១. សទ្ធាពល កម្លាំង គឺ ជំនឿ

២. វិរិយពល កម្លាំង គឺ សេចក្ដីព្យាយាម

៣. ហិរិពល កម្លាំង គឺ សេចក្ដីខ្មាសបាប

៤. ឱត្តប្បពល កម្លាំង គឺ សេចក្ដីខ្លាចបាប

៥. សតិពល កម្លាំង គឺ សេចក្ដីនឹករឭក

៦. សមាធិពល កម្លាំង គឺ ការតាំងចិត្តមាំ

៧. បញ្ញាពល កម្លាំង គឺ សេចក្ដីដឹងច្បាស់ ។

## អនុសយ កិលេសដេកត្រាំក្នុងចិត្ត ៧

១. កាមរាគានុសយ អនុស័យ គឺ សេចក្ដីត្រេកអរក្នុងកាម

២. បដិឃានុសយ អនុស័យ គឺ សេចក្ដីថ្នាំងថ្នាក់ចិត្ត

៣. ទិដ្ឋានុសយ អនុស័យ គឺ ទិដ្ឋិយល់ឃើញខុស

៤. វិចិកិច្ឆានុសយ អនុស័យ គឺ សេចក្ដីសង្ស័យ

www.budinst.gov.kh www.elibraryofcambodia.org

៥. មានានុសយ អនុស័យ គឺ មានះ

៦. ភវរាគានុសយ អនុស័យ គឺ សេចក្តីត្រេកអរក្នុងភព

៧. អវិជ្ជានុសយ អនុស័យ គឺ អវិជ្ជា ។

### វិធីលះអាសវៈ ៧

១. លះដោយ ទស្សនៈ ការយល់ឃើញ

២. លះដោយ សំវរៈ ការសង្រួម

៣. លះដោយ បដិសេវនៈ ការសេព

៤. លះដោយ អធិវាសនៈ ការអត់ធន់

៥. លះដោយ បរិវជ្ជនៈ ការវៀរ

៦. លះដោយ វិនោទនៈ ការបន្ទោបង់

៧. លះដោយ ភាវនា ការអប់រំ ។

### ភត្តានាំឱ្យសាបសូន្យនៃអ្នកបដិបត្តិធម៌ ៧

១. ចូលចិត្ត ធ្វើការងារ

២. ចូលចិត្ត និយាយ

៣. ចូលចិត្ត ដេក

៤. ចូលចិត្ត ការពពាក់ពពូន

www.budinst.gov.kh www.elibraryofcambodia.org

៥. មិនសង្រួមឥន្ទ្រីយ៍ ៦

៦. មិនស្គាល់ប្រមាណក្នុងភោជន

៧. ចូលចិត្តធ្វើការងារដែលមិនមែនជាភារៈរបស់ខ្លួន ។

### អនុបុព្វបដិបទា បដិបត្តិតាមលំដាប់ ៧

១. រក្សាសីល

២. សង្រួមឥន្ទ្រីយ៍ ៦

៣. ស្គាល់ប្រមាណក្នុងភោជន

៤. ព្យាយាមភ្ញាក់រឭក

៥. មាន សតិសម្បជញ្ញៈ

៦. ធ្វើសមាធិ ជម្រះចិត្តចាកនីវរណៈ

៧. ស្ងាត់ចាកកាម ចាកអកុសល សម្រេចដល់ឈានទី ១ រហូត ឈានទី ៤ ។

### ធម៌នាំឱ្យសម្រេចបដិសម្ភិទា ៧

១. កាលចិត្តខ្ជិលច្រអូស ដឹងច្បាស់

២. កាលចិត្តរួញរា ដឹងច្បាស់

៣. កាលចិត្តរាយមាយ ដឹងច្បាស់

៤. កាលវេទនា កើតរលត់ ដឹងច្បាស់

www.budinst.gov.kh www.elibraryofcambodia.org

៥. កាលសញ្ញា កើត រលត់ ដឹងច្បាស់

៦. វិតក្ក កើត រលត់ ដឹងច្បាស់

៧. ធម៌ទាំងឡាយ ជាទីសប្បាយ មិនជាទីសប្បាយ ថោកទាប ប្រណិត ខ្មៅ ស ស្របគ្នា ឬទំនាស់គ្នា រៀនសូត្រ ធ្វើទុកក្នុងចិត្ត ចងចាំ ដឹងច្បាស់ល្អ នូវហេតុនោះ ដោយបញ្ញា៕

## ឧបាយកែងោកងុយ ៧

១. បើធ្វើទុកនូវសញ្ញាណាហើយងោកងុយ គប្បីធ្វើទុកនូវសញ្ញានោះឲ្យច្រើនឡើងៗទៀត នឹងបាត់ងោកងុយ ។

២. បើនៅតែមិនបាត់ងោកងុយ គប្បីត្រិះរិះ រំពឹងពិចារណាធម៌ដែលខ្លួនធ្លាប់ស្តាប់ ធ្លាប់រៀនសូត្រ ឲ្យច្រើនៗ នឹងបាត់ងោកងុយ ។

៣. បើនៅតែមិនបាត់ងោកងុយ គប្បីស្វាធ្យាយ(សូត្រក្នុងចិត្ត) នូវធម៌ដែលខ្លួនរៀនសូត្រហើយឲ្យច្រើនៗនឹងបាត់ងោកងុយ។

៤. បើនៅតែមិនបាត់ងោកងុយ គប្បីយកដៃឆ្កៀលត្រចៀក និងស្ទាបអង្អែលខ្លួន នឹងបាត់ងោកងុយ ។

៥. បើនៅតែមិនបាត់ងោកងុយ គប្បីក្រោកយកទឹកលប់មុខ សម្លឹងមើលទិសផ្សេងៗ នឹងបាត់ងោកងុយ ។

www.budinst.gov.kh www.elibraryofcambodia.org

៦. បើនៅតែមិនបាត់ងោកងុយ គប្បីធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា អធិដ្ឋានថា ថ្ងៃយ៉ាងណា យប់ក៏យ៉ាងនោះ យប់យ៉ាងណា ថ្ងៃក៏យ៉ាងនោះ នឹងបាត់ងោកងុយ ។

៧. បើនៅតែមិនបាត់ងោកងុយ គប្បីដើរចង្ក្រមនឹងបាត់ងោកងុយ បើនៅតែមិនបាត់ងោកងុយទៀត គប្បីរកកន្លែងដេកមានសតិសម្បជញ្ញៈធ្វើទុកក្នុងចិត្ត នូវឧដ្ឋានសញ្ញា ថានឹងក្រោកឡើងបដិបត្តិធម៌ទៀត ។

## សមាធិបរិក្ខារ ៧

១. សម្មាទិដ្ឋិ ២. សម្មាសង្កប្បោ ៣. សម្មាវាចា
៤. សម្មាកម្មន្តោ ៥. សម្មាអាជីវោ ៦. សម្មាវាយាមោ
៧. សម្មាសតិ ។ល។

## ពោជ្ឈង្គ ៧

១. សតិ សេចក្តីនឹករឭក ២. ធម្មវិចយៈ ការជ្រើសរើសធម៌
៣. វីរិយ សេចក្តីព្យាយាម ៤. បីតិ សេចក្តីឆ្អែតចិត្ត
៥. បស្សទ្ធិ សេចក្តីស្ងប់កាយ ស្ងប់ចិត្ត ៦.សមាធិ ចិត្តតាំងមាំ
៧. ឧបេក្ខា ចិត្តជាកណ្តាល ។

www.budinst.gov.kh www.elibraryofcambodia.org

## វិសុទ្ធិ ៧

១. សីលវិសុទ្ធិ សេចក្ដីបរិសុទ្ធិនៃសីល

២. ចិត្តវិសុទ្ធិ សេចក្ដីបរិសុទ្ធិនៃចិត្ត

៣. ទិដ្ឋិវិសុទ្ធិ សេចក្ដីបរិសុទ្ធិនៃការឃើញ

៤. កង្ខាវិតរណវិសុទ្ធិ សេចក្ដីបរិសុទ្ធិនៃញាណជាគ្រឿងកន្លងផុតសេចក្ដីសង្ស័យ ។

៥. មគ្គាមគ្គញាណទស្សនវិសុទ្ធិ សេចក្ដីបរិសុទ្ធិនៃញាណ ជាគ្រឿងឃើញថា នេះជាផ្លូវ នេះមិនមែនជាផ្លូវ ។

៦. បដិបទាញាណទស្សនវិសុទ្ធិ សេចក្ដីបរិសុទ្ធិនៃញាណ ជាគ្រឿងឃើញបដិបទា ដែលនឹងឲ្យអរិយមគ្គកើតឡើង ។

៧. ញាណទស្សនវិសុទ្ធិ សេចក្ដីបរិសុទ្ធិនៃញាណទស្សនៈ គឺឃើញមគ្គទាំង ៤ ។

## ធម៌ញុំាងចិត្តឱ្យប្រព្រឹត្តទៅក្នុងអំណាច ៧

១. សមាធិកុសលោ ឈ្លាសក្នុងសមាធិ

២. សមាបត្តិកុសលោ ឈ្លាសក្នុងការចូលសមាធិ

៣. ឋិតិកុសលោ ឈ្លាសក្នុងការតាំងនៅនៃសមាធិ

www.budinst.gov.kh www.elibraryofcambodia.org

៤. វុដ្ឋានកុសលោ ឈ្លាសក្នុងការចេញចាកសមាធិ
៥. កល្លិតកុសលោ ឈ្លាសក្នុងការចែករំលែកសមាធិ
៦. គោចរកុសលោ ឈ្លាសក្នុងគោចរ (អារម្មណ៍) នៃសមាធិ
៧. អភិហារកុសលោ ឈ្លាសក្នុងការនាំមកនូវសមាធិ ៕

## ធម៌ពួក ៨

១. សោតាបន្នោ អ្នកសម្រេចសោតាបត្តិផលហើយ
២. អ្នកនៅក្នុង សោតាបត្តិមគ្គ
៣. សកទាគាមី អ្នកសម្រេចសកទាគាមិផលហើយ
៤. អ្នកនៅក្នុង សកទាគាមិមគ្គ
៥. អនាគាមី អ្នកសម្រេចអនាគាមិផលហើយ
៦. អ្នកនៅក្នុង អនាគាមិមគ្គ
៧. អរហន្តោ អ្នកសម្រេចអរហត្តផលហើយ
៨. អ្នកនៅក្នុង អរហត្តមគ្គ ។

## អវិជ្ជា ៨

១. ទុក្ខេ អញ្ញាណំ មិនដឹងច្បាស់ទុក្ខ
២. ទុក្ខសមុទយេ អញ្ញាណំ មិនដឹងច្បាស់ហេតុឲ្យទុក្ខកើត
៣. ទុក្ខនិរោធេ អញ្ញាណំ មិនដឹងច្បាស់ការរលត់ទុក្ខ

www.budinst.gov.kh www.elibraryofcambodia.org

៤. ទុក្ខនិរោធគាមិនិបដា បដិបទាយ អញ្ញាណំ មិនដឹងច្បាស់

បដិបទាឲ្យដល់នូវការរលត់ទុក្ខ

៥. បុព្វន្តេ អញ្ញាណំ មិនដឹងច្បាស់អតីត

៦. អបរន្តេ អញ្ញាណំ មិនដឹងច្បាស់អនាគត

៧. បុព្វន្តាបរន្តេ អញ្ញាណំ មិនដឹងច្បាស់អតីតនិងអនាគត

៨. ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ មិនដឹងច្បាស់ធម៌ទាំងឡាយដែលអាស្រ័យគ្នាកើតមានឡើង

តាមគោល ឥទប្បច្ចយតា ។

## វិជ្ជា ៨

១. វិបស្សនាញាណ ញាណក្នុងវិបស្សនា

២. មនោមយិទ្ធិ ឫទ្ធិសម្រេចដោយចិត្ត

៣. ឥទ្ធិវិធិ សម្ដែងឫទ្ធិផ្សេងៗបាន

៤. ទិព្វសោត ត្រចៀកទិព្វ

៥. ចេតោបរិយញ្ញាណ ដឹងចិត្តអ្នកដទៃ

៦. បុព្វេនិវាសានុស្សតិញ្ញាណ រឭកជាតិបាន

៧. ទិព្វចក្ខុ (ចុតូបបាតញាណ) ភ្នែកទិព្វ

៨. អាសវក្ខយញ្ញាណ ញាណក្នុងការធ្វើឲ្យអស់នូវអាសវៈ ។

www.budinst.gov.kh www.elibraryofcambodia.org

អដ្ឋង្គិកមគ្គ ផ្លូវប្រកបដោយអង្គ ៨

១. សម្មាទិដ្ឋិ ការយល់ឃើញត្រូវ

២. សម្មាសង្កប្បោ សេចក្តីត្រិះរិះត្រូវ

៣. សម្មាវាចា ពាក្យសំដីត្រូវ

៤. សម្មាកម្មន្តោ ការងារត្រូវ

៥. សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ

៦. សម្មាវាយាមោ សេចក្តីព្យាយាមត្រូវ

៧. សម្មាសតិ ការរឭកត្រូវ

៨. សម្មាសមាធិ ចិត្តតាំងមាំត្រូវ ។

ឈាន ៨ ឬ សមាបត្តិ ៨

រូបជ្ឈាន ៤ អរូបជ្ឈាន ៤ ហៅថា ឈាន ៨ ឬ សមាបត្តិ ៨ ក៏បាន ។

កត្តានាំឱ្យសាបសូន្យដល់អ្នកបដិបត្តិធម៌ ៨

១. កម្មារាមតា ចូលចិត្តធ្វើការងារ

២. ភស្សារាមតា ចូលចិត្តនិយាយ

៣. និទ្ទារាមតា ចូលចិត្តដេក

៤. សង្គណិការាមតា ចូលចិត្តពពាក់ពពូន

www.budinst.gov.kh www.elibraryofcambodia.org

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE



៥. ឥន្ទ្រិយេសុ អគុត្តទ្វារតា មិនសង្រួមក្នុងឥន្ទ្រិយ ៦

៦. ភោជនេ អមត្តញ្ញុតា មិនស្គាល់ប្រមាណក្នុងភោជន

៧. សំសគ្គារាមតា ត្រេកអរក្នុងការជាប់ជំពាក់

៨. បបញ្ចារាមតា ត្រេកអរក្នុងធម៌ជាគ្រឿងយឺតយូរ ។

## ធម៌ជាបច្ច័យតៗគ្នា ៨

១. សតិសម្បជញ្ញៈ ជាបច្ច័យឲ្យកើត ហិរិឱត្តប្បៈ

២. ហិរិឱត្តប្បៈ ជាបច្ច័យឲ្យកើត ឥន្ទ្រិយសំវរៈ

៣. ឥន្ទ្រិយសំវរៈ ជាបច្ច័យឲ្យកើត សីល

៤. សីល ជាបច្ច័យឲ្យកើត សម្មាសមាធិ

៥. សម្មាសមាធិ ជាបច្ច័យឲ្យកើត យថាភូតញាណទស្សនៈ

៦. យថាភូតញាណទស្សនៈ ជាបច្ច័យឲ្យកើត និព្វិទាវិរាគ

៧. និព្វិទាវិរាគ ជាបច្ច័យឲ្យកើត វិមុត្តិញាណទស្សនៈ

៨. វិមុត្តិ ជាទីបំផុតនៃការបដិបត្តិធម៌ ៕

## វិមោក្ខ ៨

បុគ្គលមានរូបជ្ឈាន រមែងឃើញនូវរូបគឺកសិណទាំងឡាយ (មាននីលកសិណជាដើម) នេះជាវិមោក្ខទី ១ ។ បុគ្គលពួកមួយ

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY



មិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង (មានសក់ជាដើម) រមែង ឃើញនូវរូបខាងក្រៅទាំងឡាយគឺកសិណ (មានទីលកសិណជា ដើម) នេះជាវិមោក្ខទី ២ ។ បុគ្គលមានចិត្តចុះស៊ប់ថា វណ្ណ កសិណដ៏បរិសុទ្ធ នេះជាវិមោក្ខទី ៣ ។ ព្រោះកន្លងនូវសញ្ញា ដោយប្រការទាំងពួង ដល់នូវសេចក្ដីវិនាសនៃបដិឃសញ្ញា មិន បានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា បានដល់នូវអាកាសានញ្ចាយត- នជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថាអាកាសមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៤ ។ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយ ការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខ ទី ៥ ។ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំង ពួងបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចក៏មិនមានដូច្នេះ នេះជាវិមោក្ខទី ៦ ។ ព្រោះកន្លងនូវ អាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវនេវ សញ្ញានាសញ្ញាយតនជ្ឈាននេះជាវិមោក្ខទី ៧ ។ ព្រោះកន្លងនូវ នេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវ សញ្ញាវេទយិតនិរោធ (សេចក្ដីរលត់នៃសញ្ញានិង វេទនា)នេះជា

www.budinst.gov.kh www.elibraryofcambodia.org

វិមោក្ខទី ៨ ។

## អភិភាយតនៈ ៨

បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិច មានសម្បុរល្អ ឬ សម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹងអាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ១ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណច្រើន មានសម្បុរល្អ ឬ សម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ២ ។ បុគ្គលពួកមួយ មិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិចមានសម្បុរល្អ ឬ សម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៣ ។ បុគ្គលពួកមួយមិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅជារូបមានប្រមាណច្រើន មានសម្បុរល្អ ឬ សម្បុរអាក្រក់គ្របសង្កត់នូវរូប

www.budinst.gov.kh www.elibraryofcambodia.org

ទាំងនោះ ហើយមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៤ ។ បុគ្គលពួកមួយមិនមានសេចក្ដីសំគាល់នូវរូបខាងក្នុងឃើញនូវរូបខាងក្រៅជារូបខៀវ មានសម្បុរខៀវ ជាទីចង្អុលប្រាប់ថា នេះមានសម្បុរខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះហើយមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈ ទី ៥ ។ បុគ្គលពួកមួយមិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅជារូបលឿង មានសម្បុរលឿង ជាទីចង្អុលប្រាប់ថា នេះមានសម្បុរលឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៦។ បុគ្គលពួកមួយ មិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅជារូបក្រហម មានសម្បុរក្រហម ជាទីចង្អុលប្រាប់ថា នេះមានសម្បុរក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៧ ។

www.budinst.gov.kh www.elibraryofcambodia.org

បុគ្គលពួកមួយ មិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបស មានសម្បុរស ជាទីចង្អុលប្រាប់ថា នេះមានសម្បុរស មានពន្លឺស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជាអភិភាយតនៈទី ៨ ។

## ធម៌ពួក ៩

អនុបុព្វវិហារ ធម៌ជាគ្រឿងនៅតាមលំដាប់ ៩

រូបជ្ឈាន ៤ អរូបជ្ឈាន ៤ និង សញ្ញាវេទយិតនិរោធ ១ ។

អនុបុព្វនិរោធ ធម៌ជាគ្រឿងរលត់តាមលំដាប់ ៩

១. ចូល បឋមឈាន កាមសញ្ញា រលត់
២. ចូល ទុតិយឈាន វិតក្ក វិចារ រលត់
៣. ចូល តតិយឈាន បីតិ រលត់
៤. ចូល ចតុត្ថឈាន អស្សាសបស្សាស រលត់
៥. ចូល អាកាសានញ្ចាយតនឈាន រូបសញ្ញា រលត់
៦. ចូល វិញ្ញាណញ្ចាយតនឈាន អាកាសានញ្ចាយតនសញ្ញា រលត់

www.budinst.gov.kh www.elibraryofcambodia.org

៧.ចូល អាកិញ្ចញ្ញាយតនឈាន វិញ្ញាណញ្ចាយតនសញ្ញា រលត់
៨.ចូល នេវសញ្ញានាសញ្ញាយតនឈាន អាកិញ្ចញ្ញាយតនសញ្ញា រលត់
៩. ចូល សញ្ញាវេទយិតនិរោធ សញ្ញា និង វេទនា រលត់ ។

## ធម៌ដែលគួរបំរើន ៩

១. សីលវិសុទ្ធិ ២. ចិត្តវិសុទ្ធិ ៣. ទិដ្ឋិវិសុទ្ធិ
៤. កង្ខាវិតរណវិសុទ្ធិ ៥. មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ
៦. បដិបទាញ្ញាណទស្សនវិសុទ្ធិ ៧. ញ្ញាណទស្សនវិសុទ្ធិ
៨. បញ្ញាវិសុទ្ធិ ៩. វិមុត្តិវិសុទ្ធិ ។

## ធម៌ដែលត្រូវលះ ៩
### មានតណ្ហាជាមូល

១. អាស្រ័យ តណ្ហា កើត បរិយេសនា ការស្វែងរក
២. អាស្រ័យ បរិយេសនា កើត លាភ ការបាន
៣. អាស្រ័យ លាភ កើត វិនិច្ឆយោ សេចក្តីត្រិះរិះ
៤. អាស្រ័យ វិនិច្ឆយ កើត ឆន្ទរាគ សេចក្តីពេញចិត្ត
៥. អាស្រ័យ ឆន្ទរាគ កើត អជ្ឈោសាន សេចក្តីជឿស៊ប់

www.budinst.gov.kh www.elibraryofcambodia.org

៦. អាស្រ័យ អជ្ឈោសាន កើត បរិគ្គហ ការហួងហែង
៧. អាស្រ័យ បរិគ្គហ កើត មច្ឆរិយ សេចក្តីកំណាញ់
៨. អាស្រ័យ មច្ឆរិយ កើត អារក្ខ ការរក្សា
៩. អាស្រ័យ អារក្ខ កើត អកុសល បាបអកុសល ជាច្រើន
គឺការកាន់ដំបង គ្រឿងសស្ត្រាវុធ ឈ្លោះទាស់ទែង ។ល។

**ធម៌ដែលត្រូវចំរើន ៩**

**មាន យោនិសោមនសិការ ជាមូល**

១.អាស្រ័យយោនិសោមនសិការ កើត បាមោជ្ជ សេចក្តីរីករាយ
២. អាស្រ័យ បាមោជ្ជ កើត បីតិ សេចក្តីត្រេកអរ
៣. អាស្រ័យ បីតិ កើត កាយបស្សទ្ធិ សេចក្តីស្ងប់កាយ
៤. អាស្រ័យ កាយបស្សទ្ធិ កើត សុខ សេចក្តីសុខចិត្ត
៥. អាស្រ័យ សុខ កើត សមាធិ ការតាំងចិត្តមាំ
៦. អាស្រ័យ សមាធិ កើត យថាភូតញ្ញាណ សេចក្តីដឹងច្បាស់ តាមពិត
៧ អាស្រ័យ យថាភូតញ្ញាណ កើត និព្វិទា សេចក្តីនឿយណាយ
៨. អាស្រ័យ និព្វិទា កើត វិរាគ សេចក្តីប្រាសចាកតម្រេក
៩. អាស្រ័យ វិរាគ កើត វិមុត្តិ ការរួចផុត ។

www.budinst.gov.kh www.elibraryofcambodia.org

## វិបស្សនាញាណ ៩

១.ឧទយព្វយញ្ញាណ បញ្ញាដឹងច្បាស់នូវការកើត និងការរលត់នៃនាមរូប ។

២.ភង្គញ្ញាណ បញ្ញាដឹងច្បាស់នូវការរលត់នៃនាមរូប ។

៣.ភយតុបដ្ឋានញ្ញាណ បញ្ញាដឹងច្បាស់នូវនាមរូបគួរឲ្យភ័យខ្លាច ។

៤.អាទីនវញ្ញាណ បញ្ញាដឹងច្បាស់នូវទោសនៃនាមរូប ។

៥.និព្វិទាញ្ញាណ បញ្ញាដឹងច្បាស់នូវនាមរូប គួរឲ្យនឿយណាយ។

៦.មុញ្ចិតុកម្យតាញ្ញាណ បញ្ញាដឹងច្បាស់នូវនាមរូបហើយប្រាថ្នាឲ្យរួចផុតពីនាមរូប ។

៧.បដិសង្ខាញ្ញាណ បញ្ញាដឹងច្បាស់នូវនាមរូបហើយគិតរកឧបាយរំដោះឲ្យផុតពីនាមរូប ។

៨.សង្ខារុបេក្ខាញ្ញាណ បញ្ញាដឹងច្បាស់នូវនាមរូប មិនស្រឡាញ់ មិនស្អប់ ហើយតាំងចិត្តជាកណ្តាល ។

៩.អនុលោមញ្ញាណ បញ្ញាដឹងច្បាស់នូវនាមរូប ហើយអនុលោមតាមញាណខាងដើមផង អនុលោមតាមពោធិបក្ខិយផង ជាហេតុឲ្យឃើញអរិយសច្ចទាំង ៤ ៕

www.budinst.gov.kh www.elibraryofcambodia.org

## ព្រះនព្វលោកុត្តរធម៌ ៩ គឺ

មគ្គ ៤ ផល ៤ និព្វាន ១ ៕

## ធម៌ពួក ១០

### បារមី ១០

១.ទាន ការឲ្យទាន ២.សីល ការរក្សាកាយវាចាឲ្យរៀបរយ ៣.នេក្ខម្ម ការចេញបួស ៤.បញ្ញា ប្រាជ្ញា ៥.វីរិយ សេចក្តីព្យាយាម ៦. ខន្តិ សេចក្តីអត់ធន់ ៧.សច្ច សេចក្តីទៀងត្រង់ ៨.អធិដ្ឋាន សេចក្តីសម្រេចចិត្តច្បាស់លាស់ ៩.មេត្តា សេចក្តីស្រឡាញ់រាប់អាន ១០. ឧបេក្ខា ការតាំងចិត្តជាកណ្តាល ។ ចែកទៅជា ៣០ គឺ បារមី១០ ឧបបារមី១០ បរមត្ថបារមី១០ ។

### បលិពោធ ១០

១. អាវាស ទីកន្លែង ២. កុល ត្រកូល ៣.លាភ លាភសក្ការៈ ៤. គណ ពួកក្រុម ៥.កម្ម ការងារ ៦.ញាតិ ញាតិសន្តាន ៧.អាពាធ ជម្ងឺដំកាត់ ៨.គន្ថ ការសិក្សារៀនសូត្រ ៩. ឥទ្ធិ ការសម្តែងឫទ្ធិ ១០. អទ្ធាន ការធ្វើដំណើរ ។

www.budinst.gov.kh www.elibraryofcambodia.org

## វិបស្សនូបក្កិលេស ១០

១. ឱភាស ពន្លឺ ២. ញាណ សេចក្តីដឹង ៣. បីតិ សេចក្តីឆ្អែតកាយ ឆ្អែតចិត្ត ៤. បស្សទ្ធិ សេចក្តីស្ងប់ត្រជាក់ ៥.សុខ សេចក្តីសុខចិត្ត ៦. អធិមោក្ខ សទ្ធាខ្លាំង ៧.បគ្គាហៈ សេចក្តីព្យាយាម ៨. ឧបដ្ឋាន សតិចាស់ក្លាច្បាស់ ៩.ឧបេក្ខា ចិត្តជាកណ្តាល ១០.និកន្តិ សេចក្តីពេញចិត្ត ។

## កិលេស ១០

១.លោភ សេចក្តីលោភលន់ ២.ទោស សេចក្តីក្រោធខឹង ៣. មោហៈ សេចក្តីវង្វេង ៤. មានៈ សេចក្តីប្រកាន់ ៥.ទិដ្ឋិ សេចក្តីយល់ឃើញខុស ៦. វិចិកិច្ឆា សេចក្តីសង្ស័យ ៧. ថីន សេចក្តីធុញ ៨. ឧទ្ធច្ច សេចក្តីអណ្តែតអណ្តូង ៩. អហិរិក សេចក្តីមិនខ្មាសបាប ១០. អនោត្តប្ប សេចក្តីមិនខ្លាចបាប ។

## សំយោជនៈ ១០

គឺ ឱរម្ភាគិយសំយោជនៈ ៥ និង ឧទ្ធម្ភាគិយសំយោជនៈ៥ ត្រូវជា ១០ បានរៀបរៀងទុកហើយ ក្នុងធម៌ ពួក ៥ ។

www.budinst.gov.kh www.elibraryofcambodia.org

## វិបស្សនាញាណ ១០

ក្នុងបាលីដើម វិបស្សនាញាណ មាន ៩ ដូចបានរៀបរៀង ទុក ក្នុងធម៌ពួក ៩ ស្រាប់ហើយ ។ ប៉ុន្តែ ក្នុងគម្ពីរ អភិធម្មត្ថសង្គហៈ បន្ថែម សម្មសនញាណ ការពិចារណា នាមរូបជាព្រះត្រៃលក្ខណ៍ ១ ទៀត ត្រូវជា ១០ ហោង ។

## អាហាររបស់ភវតណ្ហា ១០

១. អសប្បុរិសសំសេវ ការមិនសេពគប់សប្បុរស ជាអាហាររបស់ អសទ្ធម្មស្សវនៈ ការមិនស្តាប់ព្រះសទ្ធម្ម ។

២. អសទ្ធម្មស្សវនៈ ជាអាហាររបស់ អសទ្ធិយ សេចក្តីមិនជឿ

៣. អសទ្ធិយៈ ជាអាហាររបស់ អយោនិសោមនសិការៈ ។

៤. អយោនិសោមនសិការ ជាអាហាររបស់ អសតាសម្បជញ្ញៈ ការមិនមានសតិ សម្បជញ្ញៈ ។

៥. អសតាសម្បជញ្ញៈ ជាអាហាររបស់ ឥន្ទ្រិយាសំវរ ការមិនសង្រួមឥន្ទ្រិយ៍ ។

៦. ឥន្ទ្រិយាសំវរ ជាអាហាររបស់ ទុច្ចរិត ។

www.budinst.gov.kh www.elibraryofcambodia.org

៧. ទុច្ចរិត ជាអាហាររបស់ នីវរណៈ ។

៨. នីវរណៈ ជាអាហាររបស់ អវិជ្ជា ។

៩. អវិជ្ជា ជាអាហាររបស់ ភវតណ្ហា ។

១០. ភវតណ្ហា មិនមានទីបំផុតខាងដើមទេ ៕

## អាហាររបស់ វិជ្ជា និង វិមុត្តិ ១០

១. សប្បុរិសសំសេវៈ ការសេពគប់សប្បុរស ជាអាហាររបស់សទ្ធម្មស្សវនៈ ការស្ដាប់ព្រះសទ្ធម្ម ។

២. សទ្ធម្មស្សវនៈ ជាអាហាររបស់ សទ្ធា ។

៣. សទ្ធា ជាអាហាររបស់ យោនិសោមនសិការ ។

៤. យោនិសោមនសិការ ជាអាហាររបស់ សតិសម្បជញ្ញៈ។

៥. សតិសម្បជញ្ញៈ ជាអាហាររបស់ ឥន្ទ្រិយសំវរៈ ។

៦. ឥន្ទ្រិយសំវរៈ ជាអាហាររបស់ សុចរិត ។

៧. សុចរិត ជាអាហាររបស់ សតិប្បដ្ឋាន ។

៨. សតិប្បដ្ឋាន ជាអាហាររបស់ ពោជ្ឈង្គ ។

៩. ពោជ្ឈង្គ ជាអាហាររបស់ វិជ្ជា និង វិមុត្តិ ។

១០. វិជ្ជា និង វិមុត្តិ ជាផលទីបំផុត ។

www.budinst.gov.kh www.elibraryofcambodia.org

## សញ្ញា ១០

១. អនិច្ចសញ្ញា សំគាល់ថាមិនទៀង ២. អនត្តសញ្ញា សំគាល់ថា មិនមានអត្តា ៣. អសុភសញ្ញា សំគាល់ថា មិនស្អាត ៤. អាទីនវសញ្ញា សំគាល់ថា មានទោសច្រើន ៥. បហានសញ្ញា សំគាល់ថា គួរលះបង់ ៦. វិរាគសញ្ញា សំគាល់ថា ប្រាសចាកតម្រេក ៧. និរោធសញ្ញា សំគាល់ថា រលត់ ៨. សព្វលោកេ អនភិរតសញ្ញា សំគាល់ថា មិនគួរត្រេកអរក្នុងលោកទាំងពួង ៩. សព្វសង្ខារេសុ អនិច្ឆសញ្ញា សំគាល់ថាមិនគួរប្រាថ្នាក្នុង សង្ខារទាំងពួង ១០. អានាបានស្សតិ មានសតិដកដង្ហើមចេញ ចូល ៕

## ទសពិធរាជធម៌ ១០

១. ទាន ការឲ្យទាន ២. សីល ការរក្សាសីល ៥ ៣. បរិច្ចាគ ការបរិច្ចាគទ្រព្យសាងជាតិ ៤. អាវជ្ជ សេចក្តីស្មោះត្រង់ ៥. មទ្ទវៈ សេចក្តីសុភាពទន់ភ្លន់ ៦. តបៈ

www.budinst.gov.kh www.elibraryofcambodia.org

ការរក្សាឧបោសថ ផុតកិលេសផ្សេង ៗ និង ផុតអ្នកធ្វើខុសឲ្យទទួលទោសតាមច្បាប់ ៧. អក្កោធន មិនក្រេវក្រោធ ៨.អវិហឹសា មិនបៀតបៀន ៩. ខន្តិ សេចក្តីអត់ធន់ ១០ អវិរោធន មិនបំពានលើច្បាប់ ៕

## ធម៌ពួក ១១

## អានិសង្សការចំរើនមេត្តា ១១

១. សុខំ សុបតិ ដេកលក់ស្រួល

២. សុខំ បដិពុជ្ឈតិ ភ្ញាក់ឡើងស្រួល

៣. ន បាបកំ សុបិនំ បស្សតិ មិនយល់សប្តិអាក្រក់

៤. មនុស្សានំ បិយោ ហោតិ ជាទីស្រឡាញ់របស់ពួកមនុស្ស

៥. អមនុស្សានំ បិយោ ហោតិ ជាទីស្រឡាញ់របស់ពួកអមនុស្ស

៦. ទេវតា រក្ខន្តិ ទេវតាតែងថែរក្សា

៧.នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ រមែងឆ្លងផុតពីភ្លើង ថ្នាំពិស ឬ សស្ត្រាវុធ

៨. តុវដំ ចិត្តំ សមាធិយតិ ចិត្តឆាប់តាំងមាំជាសមាធិ

៩. មុខវណ្ណោ វិប្បសីទតិ សម្បុរមុខស្រស់បស់

www.budinst.gov.kh www.elibraryofcambodia.org

១០. អសម្មុឡ្ហោ កាលំ ករោតិ ពេលស្លាប់មិនវង្វេង

១១. ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ បើមិនទាន់បានចាក់ធ្លុះធម៌ដ៏ក្រៃលែង រមែងទៅកើតក្នុងព្រហ្មលោក ។

## ធម៌ពួក ១២

## ទុក្ខ ១២ កង

១. ជាតិទុក្ខ ការកើតជាទុក្ខ

២. ជរាទុក្ខ ការចាស់គ្រាំគ្រាជាទុក្ខ

៣. មរណទុក្ខ សេចក្តីស្លាប់ជាទុក្ខ

៤. សោកទុក្ខ សេចក្តីក្រៀមក្រំជាទុក្ខ

៥. បរិទេវទុក្ខ សេចក្តីខ្សឹកខ្សួលជាទុក្ខ

៦. ទុក្ខទុក្ខ សេចក្តីលំបាកកាយជាទុក្ខ

៧. ទោមនស្សទុក្ខ ការអាក់អន់ចិត្តជាទុក្ខ

៨. ឧបាយាសទុក្ខ ការតានតឹងចិត្តជាទុក្ខ

៩. អប្បិយេហិ សម្បយោគទុក្ខ ការជួបប្រសព្វដោយសត្វ និង សង្ខារ មិនជាទីស្រឡាញ់ទាំងឡាយ ជាទុក្ខ

www.budinst.gov.kh www.elibraryofcambodia.org

១០. បិយេហិ វិប្បយោគទុក្ខ ការព្រាត់ប្រាសចាកសត្វ និង សង្ខារ ជាទីស្រឡាញ់ទាំងឡាយ ជាទុក្ខ

១១. យម្បិច្ឆំ ន លភតិ តម្បិទុក្ខ ប្រាថ្នារបស់ណាមិនបាន នោះក៏ជាទុក្ខ

១២. សង្ខិត្តេន បញ្ចុបាទានក្ខន្ធទុក្ខ ពោលដោយបំប្រួញ ឧបាទានក្ខន្ធទាំង ៥ ជាទុក្ខ ។

## អាយតនៈ ១២ គឺ

អាយតនៈខាងក្នុង ៦ និង អាយតនៈខាងក្រៅ ៦

## កម្ម ១២

### កម្មឱ្យផលតាមកិច្ច ៤

១. ជនកកម្ម កម្មមានកិច្ចជាអ្នកបង្កើត ជាតួនាំសត្វឲ្យកើតក្នុងភពថ្មី ។

២. ឧបត្ថម្ភកកម្ម កម្មមានកិច្ចជួយជ្រោមជ្រែងជនកកម្ម ។

៣. ឧបបីឡកកម្ម កម្មមានកិច្ចបៀតបៀនជនកកម្ម ។

៤.ឧបឃាតកកម្ម កម្មមានកិច្ចផ្តាច់បង់នូវជនកកម្ម និងកម្មដទៃ។

www.budinst.gov.kh www.elibraryofcambodia.org

## កម្មឱ្យផលតាមលំដាប់មុនក្រោយ ៤

១. គរុកម្ម កម្មមានទម្ងន់ (ឲ្យផលមុនគេ)

២. អាសន្នកម្ម កម្មដែលគេធ្វើពេលជិតស្លាប់

៣. អាចិណ្ណកម្ម (ពហុលកម្ម) កម្មដែលគេធ្វើរឿយៗ

៤. កដត្តាកម្ម កម្មដែលគេធ្វើដោយឥតចេតនា ឬ មានចេតនាខ្សោយ ។

## កម្មឱ្យផលតាមលំដាប់ពេលវេលា ៤

១. ទិដ្ឋធម្មវេទនីយកម្ម កម្មឲ្យផលក្នុងបច្ចុប្បន្ន ។

២. ឧបបជ្ជវេទនីយកម្ម កម្មឲ្យផលក្នុងជាតិបន្ទាប់ពីបច្ចុប្បន្ន

៣. អបរាបរិយវេទនីយកម្ម កម្មឲ្យផលក្នុងជាតិបន្តទៅមុខទៀត

៤. អហោសិកម្ម កម្មដែលមិនឲ្យផល ។

## បច្ចយាការ ឬ បដិច្ចសមុប្បាទ ១២

១. **អវិជ្ជា** ជាបច្ច័យឲ្យកើត សង្ខារ

២. **សង្ខារ** ជាបច្ច័យឲ្យកើត វិញ្ញាណ

៣. **វិញ្ញាណ** ជាបច្ច័យឲ្យកើត នាមរូប

www.budinst.gov.kh www.elibraryofcambodia.org

៤. នាមរូប ជាបច្ច័យឲ្យកើត សឡាយតនៈ

៥. សឡាយតនៈ ជាបច្ច័យឲ្យកើត ផស្សៈ

៦. ផស្សៈ ជាបច្ច័យឲ្យកើត វេទនា

៧. វេទនា ជាបច្ច័យឲ្យកើត តណ្ហា

៨. តណ្ហា ជាបច្ច័យឲ្យកើត ឧបាទាន

៩. ឧបាទាន ជាបច្ច័យឲ្យកើត ភព

១០. ភព ជាបច្ច័យឲ្យកើត ជាតិ

១១. ជាតិ ជាបច្ច័យឲ្យកើត ជរា មរណៈ

១២. ជរា មរណៈ ជាទីបញ្ចប់នៃជាតិនីមួយៗ ។

## ធម៌ពួក ១៣

## ធុតង្គ ១៣

១. បង្សុកូលិកង្គៈ អ្នកទ្រទ្រង់សំពត់បង្សុកូលជាវត្ត

២. តេចីវរិកង្គៈ អ្នកទ្រទ្រង់ត្រៃចីវរ (ត្រឹម៣) ជាវត្ត

៣. បិណ្ឌបាតិកង្គៈ អ្នកត្រាច់បិណ្ឌបាតជាវត្ត(អត់មានកំណត់)

៤. សបទានចារិកង្គៈ អ្នកត្រាច់បិណ្ឌបាតតាមលំដាប់ជាវត្ត (មានកំណត់)

www.budinst.gov.kh www.elibraryofcambodia.org

៥. ឯកាសនិកង្គៈ អ្នកឆាន់១ថ្ងៃតែម្តង

៦. បត្តបិណ្ឌិកង្គៈ អ្នកឆាន់តែក្នុងបាត្រ

៧. ខលុបច្ឆាភត្តិកង្គៈ អ្នកឆាន់អាហារតាមដែលខ្លួនកំណត់ មិន ទទួលអាហារក្រោយពីកំណត់ហើយ

៨. អារញ្ញិកង្គៈ អ្នកនៅក្នុងព្រៃជាវត្ត

៩. រុក្ខមូលិកង្គៈ អ្នកនៅទៀបគល់ឈើជាវត្ត

១០. អព្ភោកាសិកង្គៈ អ្នកនៅក្នុងទីវាលជាវត្ត

១១. សោសានិកង្គៈ អ្នកនៅក្នុងព្រៃស្មសានជាវត្ត

១២. យថាសន្ថតិកង្គៈ អ្នកនៅក្នុងសេនាសនៈតាមមានតាមបាន

១៣. នេសជ្ជិកង្គៈ អ្នកប្រើឥរិយាបថអង្គុយជាវត្ត ៕

## ចិត្តមាននាទី(កិច្ច) ១៤

| | |
|---|---|
| ១. បដិសន្ធិកិច្ច | នាទីតភពជាតិ |
| ២. ភវង្គកិច្ច | នាទីជាអង្គនៃភព |
| ៣. អាវជ្ជនកិច្ច | នាទីនឹករកអារម្មណ៍ |
| ៤. ទស្សនកិច្ច | នាទីឃើញរូប |

www.budinst.gov.kh www.elibraryofcambodia.org

៥. សវនកិច្ច  នាទីឮសម្លេង

៦. ឃាយនកិច្ច  នាទីធុំក្លិន

៧. សាយនកិច្ច  នាទីដឹងរស

៨. ផុស្សនកិច្ច  នាទីប៉ះទង្គិច

៩. សម្បដិច្ឆន្នកិច្ច  នាទីទទួលអារម្មណ៍

១០. សន្តីរណកិច្ច  នាទីពិចារណាអារម្មណ៍

១១. វោដ្ឋព្វនកិច្ច  នាទីកាត់សេចក្តីអារម្មណ៍

១២. ជវនកិច្ច  នាទីសោយអារម្មណ៍

១៣. តទាលម្ពនកិច្ច  នាទីទទួលអារម្មណ៍ពីជវនៈ

១៤. ចុតិកិច្ច  នាទីឃ្លាតចាកភពចាស់ ៕

## ចរណៈ ១៥

១. សីលសំវរៈ  សង្រួមក្នុងសីល

២. ឥន្ទ្រីយសំវរៈ  សង្រួមឥន្ទ្រីយ៍

៣. ភោជនេ មត្តញ្ញុតា  ដឹងប្រមាណក្នុងភោជន

៤. ជាគរិយានុយោគ  ប្រកបរឿយៗក្នុងការភ្ញាក់រឭក

៥. សទ្ធា  មានជំនឿត្រឹមត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

| | | |
|---|---|---|
| ៦. | ហិរិ | សេចក្តីខ្មាសបាប |
| ៧. | ឱត្តប្ប | សេចក្តីខ្លាចបាប |
| ៨. | ពាហុសច្ច | ការចេះចាំច្រើន |
| ៩. | វិរិយ | (ឧបក្កម) សេចក្តីព្យាយាម |
| ១០. | សតិ | សេចក្តីនឹករឭក |
| ១១. | បញ្ញា (មតិ) | សេចក្តីដឹង |
| ១២. | បឋមឈាន | ឈានទី១ |
| ១៣. | ទុតិយឈាន | ឈានទី២ |
| ១៤. | តតិយឈាន | ឈានទី៣ |
| ១៥. | ចតុត្ថឈាន | ឈានទី៤ ។ |

## ញាណ ១៦

១. នាមរូបបរិច្ឆេទញាណ ញាណកំណត់ចែក នាម និង រូប

២. បច្ចយបរិគ្គហញាណ ញាណកំណត់ដឹងបច្ច័យនៃនាមនិងរូប

៣. សម្មសនញាណ ញាណកំណត់ពិចារណានាម និងរូប ជាព្រះត្រៃលក្ខណ៍ ។ ៤. តាំងពីញាណទី ៤ រហូតដល់ញាណទី ១២ គឺ វិបស្សនាញាណទាំង ៩ ហ្នឹងឯង ។

www.budinst.gov.kh www.elibraryofcambodia.org

១៣. គោត្រភូញាណ ញាណឆ្លងចាកគោត្របុថុជ្ជន ទៅកាន់គោត្រអរិយៈ

១៤. មគ្គញាណ ញាណក្នុងអរិយមគ្គទាំង ៤

១៥. ផលញាណ ញាណក្នុងអរិយផលទាំង ៤

១៦. បច្ចវេក្ខណញាណ ញាណពិចារណាពិនិត្យមើលមគ្គផល កិលេសដែលបានលះហើយ កិលេសដែលមិនទាន់បានលះ និង ព្រះនិព្វាន ។

## ធាតុ ១៨

១. ចក្ខុធាតុ ធាតុគឺ ចក្ខុ

២. សោតធាតុ ធាតុគឺ សោត

៣. ឃានធាតុ ធាតុគឺ ឃាន

៤. ជិវ្ហាធាតុ ធាតុគឺ ជីវ្ហា

៥. កាយធាតុ ធាតុគឺ កាយ

៦. មនោធាតុ ធាតុគឺ ចិត្ត

៧. រូបធាតុ ធាតុគឺ រូប

៨. សទ្ទធាតុ ធាតុគឺ សម្លេង

www.budinst.gov.kh www.elibraryofcambodia.org

៩. គន្ធធាតុ ធាតុគឺ ក្លិន
១០. រសធាតុ ធាតុគឺ រស
១១. ផោដ្ឋព្វធាតុ ធាតុគឺ ផោដ្ឋព្វ
១២. ធម្មធាតុ ធាតុគឺ ធម៌
១៣. ចក្ខុវិញ្ញាណធាតុ ធាតុគឺ ចក្ខុវិញ្ញាណ
១៤. សោតវិញ្ញាណធាតុ ធាតុគឺ សោតវិញ្ញាណ
១៥. ឃានវិញ្ញាណធាតុ ធាតុគឺ ឃានវិញ្ញាណ
១៦. ជិវ្ហាវិញ្ញាណធាតុ ធាតុគឺ ជិវ្ហាវិញ្ញាណ
១៧. កាយវិញ្ញាណធាតុ ធាតុគឺ កាយវិញ្ញាណ
១៨. មនោវិញ្ញាណធាតុ ធាតុគឺ មនោវិញ្ញាណ ។

## ឥន្ទ្រិយ៍ ២២

១. ចក្ខុន្ទ្រិយ ឥន្ទ្រីយ៍គឺ ចក្ខុ
២. សោតិន្ទ្រិយ ឥន្ទ្រីយ៍គឺ សោត
៣. ឃានិន្ទ្រិយ ឥន្ទ្រីយ៍គឺ ឃាន
៤. ជិវ្ហិន្ទ្រិយ ឥន្ទ្រីយ៍គឺ ជិវ្ហា
៥. កាយិន្ទ្រិយ ឥន្ទ្រីយ៍គឺ កាយ

www.budinst.gov.kh www.elibraryofcambodia.org

៦. មនិន្រ្ទិយ ឥន្រ្ទីយ៍គឺ ចិត្ត
៧. ឥត្ថិន្រ្ទិយ ឥន្រ្ទីយ៍គឺ ភាវៈជាស្រ្តី
៨. បុរិសិន្រ្ទិយ ឥន្រ្ទីយ៍គឺ ភាវៈជាបុរស
៩. ជីវិតិន្រ្ទិយ ឥន្រ្ទីយ៍គឺ ជីវិត
១០. សុខិន្រ្ទិយ ឥន្រ្ទីយ៍គឺ សេចក្តីសុខ
១១. ទុក្ខិន្រ្ទិយ ឥន្រ្ទីយ៍គឺ សេចក្តីទុក្ខ
១២. សោមនស្សិន្រ្ទិយ ឥន្រ្ទីយ៍គឺ សេចក្តីសោមនស្ស
១៣. ទោមនស្សិន្រ្ទិយ ឥន្រ្ទីយ៍គឺ សេចក្តីទោមនស្ស
១៤. ឧបេក្ខិន្រ្ទិយ ឥន្រ្ទីយ៍គឺ ឧបេក្ខា
១៥. សទ្ធិន្រ្ទិយ ឥន្រ្ទីយ៍គឺ សទ្ធា
១៦. វីរិយិន្រ្ទិយ ឥន្រ្ទីយ៍គឺ វីរិយ
១៧. សតិន្រ្ទិយ ឥន្រ្ទីយ៍គឺ សតិ
១៨. សមាធិន្រ្ទិយ ឥន្រ្ទីយ៍គឺ សមាធិ
១៩. បញ្ញិន្រ្ទិយ ឥន្រ្ទីយ៍គឺ បញ្ញា
២០. អនញ្ញតញ្ញស្សាមិតិន្រ្ទិយ ឥន្រ្ទីយ៍គឺ សេចក្តីដឹងថា យើងនឹងដឹងធម៌ (ព្រះនិព្វាន) ដែលមិនទាន់បានដឹង(បានដល់សោតាបត្តិមគ្គញ្ញាណ)

www.budinst.gov.kh www.elibraryofcambodia.org

២១. អញ្ញិន្ទ្រីយ ឥន្ទ្រីយ៍គឺ កិរិយាត្រាស់ដឹងនូវធម៌(បានដល់សោតាបត្តិផលញាណជាដើម អរហត្តមគ្គញាណជាបរិយោសាន)

២២. អញ្ញាតាវិន្ទ្រីយ ឥន្ទ្រីយ៍គឺ អរហត្តផល ដែលបុគ្គលដឹងច្បាស់ហើយ ៕

**ពោធិបក្ខិយធម៌ ៣៧ គឺ**

| | | |
|---|---|---|
| ១. | សតិប្បដ្ឋាន | ៤ |
| ២. | សម្មប្បធាន | ៤ |
| ៣. | ឥទ្ធិបាទ | ៤ |
| ៤. | ឥន្ទ្រីយ | ៥ |
| ៥. | ពលៈ | ៥ |
| ៦. | ពោជ្ឈង្គ | ៧ |
| ៧ | មគ្គ(អដ្ឋង្គិកមគ្គ) | ៨ |

សូមអញ្ជើញមើល តាមធម៌ពួកនោះៗ ដែលបានរៀបរៀងទុកក្នុងខាងដើមសព្វគ្រប់អស់ហើយ ។

**ចប់**

www.budinst.gov.kh www.elibraryofcambodia.org

# លោក-អ្នកសប្បុរសដែលជួយឧបត្ថម្ភការបោះពុម្ព

១- គ្រួសារ គួច ហេង ៧៥ អ៊ឺរ៉ូ
២- ឧបាសក ស៊ុម ប៊ុត ឧបាសិកា គីម ហ៊ាង ៦០ អ៊ឺរ៉ូ
៣- ឧបាសិកា ឡាយ រ៉ុ ៦០ អ៊ឺរ៉ូ
៤- ឧបាសិកា លាង ស៊ុម ៦០ អ៊ឺរ៉ូ
៥- លោក ថ្លាង បូ និង គ្រួសារ ៥០ អ៊ឺរ៉ូ
៦- ឧបាសិកា ប៉ែ លិន ៣០ អ៊ឺរ៉ូ
៧- ឧបាសក តាន់ ណាំ ឧបាសិកា លឹម ឆេងអ៊ុ ៣០ អ៊ឺរ៉ូ
៨- ឧបាសក ណៃ ហួរ ៣០ អ៊ឺរ៉ូ
៩- លោក និង លោកស្រី ខៀវ ឡេង ៣០ អ៊ឺរ៉ូ
១០- ឧបាសក មិន ធូ ឧបាសិកា តាំង វួច ប៉ៅ ៣០ អ៊ឺរ៉ូ
១១- អ្នកស្រី ប៉ោង គិមគន និងអ្នកស្រី វ៉ា វ៉ាណា ៣០អ៊ឺរ៉ូ
១២- ឧបាសិកា ឈា ឆាត់ឌី ២០ អ៊ឺរ៉ូ
១៣- ឧបាសិកា អ៊ុំង-ម៉ាឡេង ១៥ អ៊ឺរ៉ូ
១៤- ឧបាសិកា ប៉ូអាន ស៊ីវុត្ថា ២០ អ៊ឺរ៉ូ
១៥- លោក ចៅ ហៃ និង ភរិយា ២០ អ៊ឺរ៉ូ

www.budinst.gov.kh www.elibraryofcambodia.org

១៦- លោក ប៉ុក លិមហៃ និងអ្នកស្រី ហ៊ុតគីមថាយ ២០អឺរ៉ូ

១៧- លោក ប៊ិន យ៉េ និង អ្នកស្រី ផេក មុំ ២០ អឺរ៉ូ

១៨- លោក និង លោកស្រី មូល គីណា ១៥ អឺរ៉ូ

១៩- ឧបាសិកា ឃុន តាំងអ៊ីម ១៥ អឺរ៉ូ

២០- លោក និង អ្នកស្រី ណៃវ សៃ ១៥ អឺរ៉ូ

២១- លោក និង អ្នកស្រី ស៊ាម ហ៊ុច ១៥ អឺរ៉ូ

២២- ឧបាសក ឈា ទូច (ហៅ ប៉ៅ ឡេង) និង

ឧបាសិកា ឈា សាយហាន ១៥ អឺរ៉ូ

២៣- លោក ស្រេង ច័ន្ទ ម៉ានីត និង គ្រួសារ ១៥ អឺរ៉ូ

២៤- លោក ឱ សុមេធា និង គ្រួសារ ១៥ អឺរ៉ូ

២៥- លោក ឆេង ដាវីន (Chheng Davine) ១៥ អឺរ៉ូ

២៦- Mme Sreng Danico ១៥ អឺរ៉ូ

២៧- ឧបាសិកា អេង ឡាំ ៣០ អឺរ៉ូ

២៨- ឧបាសិកា អ៊ុច ជួង ១៥ អឺរ៉ូ

២៩- ឧបាសិកា អ៊ុក សារេត ១៥ អឺរ៉ូ

៣០- ឧបាសិកា សៀប គិមហ៊ាង ១៥ អឺរ៉ូ

៣១- ឧបាសក ប៉ុន គង់សម្បត្តិ ១៥ អឺរ៉ូ

www.budinst.gov.kh www.elibraryofcambodia.org

៣២- ឧបាសិកា ឌិក ចក់សៅរឿន ១៥ អ៊ឺរ៉ូ

៣៣- ឧបាសិកា តេក ឡាយប៊ិន ៣០ អ៊ឺរ៉ូ

៣៤- M. Yi Praseth ១៥ អ៊ឺរ៉ូ

៣៥- អ្នកស្រី យី ច័ន្ទផារ៉ា ១៥ អ៊ឺរ៉ូ

៣៦- លោក សុន ណារេត អ្នកស្រី ជុង សូនីថា ៨ អ៊ឺរ៉ូ

៣៧- ឧបាសិកា សុខ ឡាង ៦០ អ៊ឺរ៉ូ

៣៨- លោក និងអ្នកស្រី យូ ណូស អាសិស ១៥ អ៊ឺរ៉ូ

៣៩- ឧបាសិកា អាត អេង ១០ អ៊ឺរ៉ូ

៤០- ឧបាសិកា នៅ ទាវខេង និង បុត្រធីតា ២០ អ៊ឺរ៉ូ

៤១- ឧបាសិកា ឈា ឡេងហាក់ ២០ អ៊ឺរ៉ូ

៤២- ឧបាសិកា ឈា ឆេងលន់ ២០ អ៊ឺរ៉ូ

៤៣- ឧបាសិកា តួ អៀនី ២០ អ៊ឺរ៉ូ

៤៤- ឧបាសិកា អៀង ហុង ១៥ អ៊ឺរ៉ូ

៤៥- ឧបាសិកា ចាន់ ណាត ១៥ អ៊ឺរ៉ូ

៤៦- ឧបាសិកា សន ខាន់ ១៥ អ៊ឺរ៉ូ

៤៧- ឧបាសិកា ង៉ិន ហុង (ពៅ) ១៥ អ៊ឺរ៉ូ

៤៨- ឧបាសិកា សាយ គីម ១៥ អ៊ឺរ៉ូ

www.budinst.gov.kh www.elibraryofcambodia.org

៤៩- ឧបាសិកា ហ៊ុល ឃុត ១៥ អឺរ៉ូ

៥០- ឧបាសិកា សុត សុផានី ១៥ អឺរ៉ូ

៥១- ឧបាសិកា ណែម លិមអ៊ាន ២០ អឺរ៉ូ

៥២- ឧបាសិកា ណែម លិមអ៊ិន ២០ អឺរ៉ូ

៥៣- ឧបាសិកា ឃិន ហុកទីវ ១៥ អឺរ៉ូ

៥៤- ឧបាសិកា ប៊ួ ដាណារ៉េត ១៥ អឺរ៉ូ

៥៥- អ្នកស្រី ចាំវ សាវេន និង ធីតា ១៥ អឺរ៉ូ

៥៦- លោកស្រី នេត្រ គួន ២០ អឺរ៉ូ

៥៧- ឧបាសិកា កុល ទូច ៤០ អឺរ៉ូ

៥៨- លោក និង លោកស្រី ហាក់ ព្រួ ១៥ អឺរ៉ូ

៥៩- លោក និង អ្នកស្រី អ៊ិន សាវេន ១៥ អឺរ៉ូ

៦០- ឧបាសិកា ស៊ុន តាំងគុយអេង ១៥ អឺរ៉ូ

៦១- ឧបាសិកា ស៊ីសុវត្ថិ ក្រិត្យនារី ១៥ អឺរ៉ូ

៦២- ឧបាសិកា ហូ គីមឡេង ១៥ អឺរ៉ូ

៦៣- លោកស្រី អ៊ូ បុប្ផ ព្រមទាំងស្វាមី ១៥ អឺរ៉ូ

៦៤- នាង នង ស៊ីនេត ១៥ អឺរ៉ូ

៦៥- លោកស្រី អ៊ូ យុវតី ព្រមទាំងស្វាមី ១៥ អឺរ៉ូ

www.budinst.gov.kh www.elibraryofcambodia.org

៦៦- លោកស្រី អ៊ូ គង់ធីតា ព្រមទាំងស្វាមី ១៥ អ៊ីរ៉ូ

៦៧- លោក អ៊ូ ទិត្យា ព្រមទាំងភរិយា ១៥ អ៊ីរ៉ូ

៦៨- នាងកញ្ញា សាគូ បុប្ផាវតី ៥ អ៊ីរ៉ូ

៦៩- នាងកញ្ញា សាគូ បុប្ផាទេវី ៥ អ៊ីរ៉ូ

៧០- ឧបាសក ឡៅ ហេង និង
ឧបាសិកា តាន់ សាយយុត ១៥ អ៊ីរ៉ូ

៧១- លោក ចាន់ អាត អ្នកស្រី ឡៅ ហុងស៊ីម ១៥ អ៊ីរ៉ូ

៧២- ឧបាសិកា ញឹក សាយ៉ាន់ ១៥ អ៊ីរ៉ូ

៧៣- អ្នកស្រី ជិប ហុងយ៉េន ១៥ អ៊ីរ៉ូ

៧៤- អ្នកស្រី ឡៅ សាយយីម ១៥ អ៊ីរ៉ូ

៧៥- លោក ផុង ហុងកៅ អ្នកស្រី ឡៅ ហុងឡាយ ១៥ អ៊ីរ៉ូ

៧៦- លោក តាន់ កាង អ្នកស្រី ខា ណុកយិប ១៥ អ៊ីរ៉ូ

៧៧- លោក ជួន ទឹម អ្នកស្រី ទិត ពៅ ១៥ អ៊ីរ៉ូ

៧៨- លោក ចៅ គាន អ្នកស្រី យក់ ហាន ១៥ អ៊ីរ៉ូ

៧៩- ឧបាសិកា អៀត ស៊ីវហ៊ាង ២០ អ៊ីរ៉ូ

៨០- ឧបាសិកា អ៊ុង ហ្គេចសាង ១៥ អ៊ីរ៉ូ

៨១- ឧបាសិកា អ៊ុង ហ្គេចតេង ១៥ អ៊ីរ៉ូ

www.budinst.gov.kh www.elibraryofcambodia.org

៨២- លោក ឃួន ថ្លៃចំណាន និង

ឧបាសិកា នង នាងណយ ២០ អ៊ឺរ៉ូ

៨៣- ឧបាសក លិម ប៉ា ឧបាសិកា ឈា ប៉ាវតេ ១៥ អ៊ឺរ៉ូ

៨៤- លោក ម៉ម សិរីសុខា និងគ្រួសារ ១៥ អ៊ឺរ៉ូ

៨៥- លោក ម៉ម ខេមរិន្ទ្រ និងគ្រួសារ ១៥ អ៊ឺរ៉ូ

៨៦- លោក និង អ្នកស្រី អោម ស៊ីថា ១៥ អ៊ឺរ៉ូ

៨៧- ឧបាសក ទេព សំផន ឧបាសិកា ទេព ម្ញិះ ១៥ អ៊ឺរ៉ូ

៨៨- ឧបាសក ឱក សិរី និង

ឧបាសិកា អ៊ុង យឿន ៣០ អ៊ឺរ៉ូ

៨៩- ភិក្ខុ ផិន ភេន ឥន្ទប្បញ្ញោ ៣០ អ៊ឺរ៉ូ

យើងខ្ញុំ សូមឧទ្ទិសចំណែកបុណ្យកុសលនេះ ប្រគេន ជូនចំពោះវិញ្ញាណក្ខន្ធ លោកអ្នកដ៏មានគុណទាំងឡាយ មានគ្រូឧបជ្ឈាយាចារ្យ និង មាតាបិតាជាដើមផង ព្រមទាំងញាតិមិត្រ ទាំងឡាយផង។ សូមលោកអ្នកដ៏មានគុណជាដើមនោះ អនុមោទនាទទួលយកនូវ ឥដ្ឋមនុញ្ញផលជាទីគាប់ចិត្ត តាមសេចក្ដីជ្រះថ្លារៀងៗខ្លួន កុំបីខាន៕

www.budinst.gov.kh www.elibraryofcambodia.org

# ចតុរារក្ខភាវនា

នមាមិ ពុទ្ធំ គុណសាគរន្តំ
សត្តា សទា ហោន្តុ សុខី អវេរា
កាយោ ជិគុច្ឆោ សកលោ ទុគន្ធោ
គច្ឆន្តិ សព្វេ មរណំ តថាហំ ៕

ខ្ញុំបង្គំព្រះពុទ្ធ គុណធំផុតដូចសាគរ
ញ៉ាំងសត្វឲ្យចេញចរ ចាកសង្សារភពនានា ។
ពួកសត្វនៅសព្វឋាន សូមកុំមានពៀរវេរា
ចេះថែរក្សាគ្នា រាល់វេលាទាំងយប់ថ្ងៃ ។
កាយទាំងមូលនេះណា មានក្លិនអាក្រក់ពេកក្រៃ
គួរខ្ពើមគ្មានថ្លៃ ចូរកែខៃរកធម៌ឆាប់ ។
គ្រប់សត្វនៅសព្វឋាន ចៀសមិនបានពីក្ដីស្លាប់
ខ្លួនអញមិនយូរឆាប់ គង់តែស្លាប់ដូចគេដែរ ៕

កំណាព្យធម៌នេះ ដកស្រង់ចេញពីភូមាកម្មដ្ឋានកថា ដោយព្រះធម្មិស្សរោ. ឯក ញឹម។ រោងពុម្ពខេមរជាតិ ភ្នំពេញ ១៩៥៤ ទំព័រ ១-២។

www.budinst.gov.kh www.elibraryofcambodia.org

# ឧបេក្ខា

តាំងចិត្តនឹងមាំស្ងប់ កុំឱ្យស្អប់កុំស្រឡាញ់
ឧបេក្ខាចិត្តវិញ មានសតិសម្បជញ្ញៈ ។
ឃើញរូបឮសម្លេង មិនវង្វេងជាប់ជំពាក់
ក្លិន រស ផោដ្ឋព្វៈ និង ធម្មៈ កើតក្នុងចិត្ត
ទោះបី ខៅ ឬ ស អាក្រក់ល្អ ដ៏ប្រណិត
មិនអាចអូសទាញចិត្ត ឱ្យស្រឡាញ់ឬស្អប់ឡើយ ។
អ្នកធ្វើបានយ៉ាងនេះ ឃើញធម៌ច្បាស់ប្រាកដហើយ
ដល់ទីពឹងត្រៃលោត្រើយ សុខឥតស្បើយនិព្វានហោង ។

ង. ភ.

២៥៥.
១៣៩ក

www.budinst.gov.kh www.elibraryofcambodia.org